របាយការណ៍សិក្សាស្រាវជ្រាវស្ដីពី

# "ផលប៉ះពាល់ពីវិបត្តិនៃការរាតត្បាតជំងឺ កូវីដ ១៩ លើប្រជាកសិករនៅក្នុង ប្រទេសកម្ពុជា"




ខែសីហា ឆ្នាំ២០២០

# សេចក្តីថ្លែងអំណរគុណ

បណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍនៃសម្ព័ន្ធបងប្អូនស្រី កម្មវិធីផ្តោតទៅលើលោកខាងត្បូង និងតំណាងប្រជាកសិករពីសហគមន៍មូលដ្ឋានមួយចំនួន សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះប្រជាកសិករ ប្រជានេសាទ តំណាងសហគមន៍ដីធ្លី តំណាងសហគមន៍កសិករ/អ្នកស្រែ ព្រមទាំងក្រុមស្រាវជ្រាវសកម្មដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចសម្ភាសន៍ជាមួយក្រុមការងារស្រាវជ្រាវយើងខ្ញុំ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះប្រជាកសិករ តំណាងសហគមន៍ និងនិស្សិតស្ម័គ្រចិត្តជាច្រើននាក់ ដែលចូលរួមយ៉ាងសកម្មទាំងកម្លាំងកាយចិត្តនៅក្នុងដំណើរការសិក្សាស្រាវជ្រាវនេះទាំងមូល។

យើងខ្ញុំក៏សូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់ក្រុមការងារបច្ចេកទេសនៃសម្ព័ន្ធបងប្អូនស្រី និងសមាជិកបងប្អូនស្រីទាំងអស់ដែលបានចូលរួមចំណែកយ៉ាងសកម្មទាំងការគាំទ្រផ្នែកស្មារតី បច្ចេកទេស និងផ្តល់យោបល់មកលើដំណើរការចងក្រង និងផលិតឯកសារស្រាវជ្រាវមួយនេះ។

# មាតិកា


សេចក្តីថ្លែងអំណរគុណ........................................................................................................................១
របកគំហើញសង្ខេប ............................................................................................................................ ៣
**សេចក្តីផ្តើម**.............................................................................................................................................៨
អំពីរបាយការណ៍ ..........................................................................................................................៩
គោលបំណងការសិក្សាស្រាវជ្រាវ.......................................................................................................៩
វិធីសាស្រ្ត ...................................................................................................................................... ១០
ព័ត៌មានទូទៅរបស់ប្រជាកសិករ ......................................................................................................... ១១
**ទិដ្ឋភាពទូទៅជុំវិញការរាតត្បាត និងវិបត្តិនានាដែលបណ្តាលពីជំងឺកូវីដ១៩**..........១២
បទពិសោធពីការទទួលបានព័ត៌មានអំពីវិបត្តិ យន្តការទប់ស្កាត់ និងការដោះស្រាយ ... ១៧
បទពិសោធពីផលប៉ះពាល់នានានៃវិបត្តិការរាតត្បាតពីជំងឺកូវីដ១៩......................... ២២
ការគាំទ្រ ឬឧបត្ថម្ភពីរាជរដ្ឋាភិបាល.................................................................................. ៣២
បំណុល និងហានិភ័យធ្លាក់ក្នុងវដ្តនៃបំណុល ........................................................................... ៣៣
ស្ថានភាពទន្ក្រានដីធ្លី ធនធានធម្មជាតិ និងជម្លោះដីធ្លីនាអំឡុងជំងឺកូវីដ១៩ ............... ៣៥
ផលប៉ះពាល់ផ្សេងៗទៀតមកលើប្រជាកសិករ.................................................................... ៣៨
ការការពារខ្លួន និងវិធីសាស្រ្តដោះស្រាយ ............................................................................. ៣៨
ការគាំទ្រនានាពីអង្គការសង្គមស៊ីវិល ................................................................................. ៣៩
**សេចក្តីសន្និដ្ឋាន**......................................................................................................................................៤០
តម្រូវការ និងអនុសាសន៍................................................................................................................៤១
អនុសាសន៍ និងសំណើររបស់ប្រជាកសិករ.................................................................................... ៤៣
**ឯកសារយោង** ...........................................................................................................................................៤៥

## របកគំហើញសង្ខេប

- ការទទួលបានព័ត៌មានពីវិធាន និងយន្តការរបស់រាជរដ្ឋាភិបាល៖ ប្រជាកសិករភាគច្រើនលើសលុប ឆ្លើយថាពួកគេទទួលបានព័ត៌មានទូទៅជុំវិញការបង្ការ ការការពារខ្លួន រោគសញ្ញា និងចំនួនអ្នកមានជំងឺកូវីដ ១៩ ជារៀងរាល់ថ្ងៃ តាមរយៈសេចក្ដីប្រកាសនានារបស់ក្រសួងសុខាភិបាល។
- ស្ថានភាពសុខភាព និងការទទួលបានការថែទាំសុខភាពរបស់ប្រជាកសិករអំឡុងពេលនៃវិបត្តិពីមេរោគកូវីដ ១៩៖
    - ប្រជាកសិករចំនួនត្រឹម១១.៥ភាគរយ ថាពួកគេបានទទួលសម្ភារៈបង្ការ និងការពារខ្លួនមួយចំនួនដូចជា៖ សាប៊ូ និងអាល់កុលបើធៀបនឹងប្រជាកសិករ៨៧.៥ភាគរយផ្សេងទៀត មិនបានទទួលសម្ភារៈការពារខ្លួនដែលឧបត្ថម្ភពីរាជរដ្ឋាភិបាល ឬ អាជ្ញាធរមូលដ្ឋាននោះទេ។ ពួកគេថា បានចំណាយទៅលើសម្ភារៈទាំងនោះដើម្បីការពារអាយុជីវិតរបស់ពួកគេ និងសមាជិកនៅក្នុងគ្រួសារ។ ការណ៍នេះ បានបន្ថែមបន្ទុកមួយទៀតសម្រាប់ពួកគេដែលកំពុងប្រឈមវិបត្តិជាច្រើន។
    - ការធ្វើតេស្តរកមេរោគកូវីដ ១៩ និងការសម្រាកថែទាំព្យាបាលជំងឺនេះ គឺមិនត្រូវបានតម្រូវឲ្យបង់ថ្លៃនោះទេ។ ក្រសួងសុខាភិបាលផ្ដល់សេវាថែទាំជំងឺនេះដោយឥតគិតថ្លៃ ទោះបីជាប្រទេសកម្ពុជា កំពុងអនុវត្តនូវកម្មវិធីបង់ថ្លៃលើសេវាថែទាំ និងព្យាបាលសុខភាពក្ដី។ ការអនុវត្តនូវការមិនយកថ្លៃលើសេវាព្យាបាលជំងឺនេះ ទទួលបានការកោតសសើរពីប្រជាពលរដ្ឋខ្មែរ
    - ឧបសគ្គចម្បងដែលប្រជាកសិករជួបប្រទះទៅលើបញ្ហាសុខភាពរបស់ពួកគេ ឬសមាជិកនៅក្នុងគ្រួសារ គឺជុំវិញលទ្ធភាពចំណាយទៅលើការប្រើប្រាស់សេវាថែទាំ និងព្យាបាលសុខភាពទាំងនៅមន្ទីរពេទ្យឯកជន និងមន្ទីរពេទ្យសាធារណៈ។
    - គ្លីនិកឯកជនមួយចំនួននៅតាមមូលដ្ឋានបានសម្ដែងការរើសអើង និងមានភាពភ័យខ្លាចក្នុងការទទួលព្យាបាលអ្នកជំងឺទូទៅ ដោយហេតុផលបារម្ភថាជាជំងឺកូវីដ ១៩។ មានករណីខ្លះគ្លីនិកបដិសេធមិនទទួលព្យាបាល និងបិទគ្លីនិកតែម្ដង។
- ផលប៉ះពាល់មកលើប្រភពចំណូល និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាកសិករ៖
    - ប្រជាកសិករជាងពាក់កណ្ដាល (៥០.៥ភាគរយ) បានកំពុងបន្តផលិតកសិផល ឬដាំដំណាំក្នុងអំឡុងពេលនេះ។ ប្រជាកសិករ៤៩.៥ភាគរយ មិនបានផលិត ឬដាំដំណាំទេដោយសារតែបញ្ហាកង្វះទឹកដែលបណ្ដាលពីភាពរាំងស្ងួត។
    - ក្នុងចំណោមប្រជាកសិករដែលកំពុងផលិត ឬដាំដំណាំនេះទៀតសោត ចំនួន៥៤.២ភាគរយ

ថាពួកគេមិនមានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម។ នៅពេលដែរប្រជាកសិករ៤៥.៨ភាគរយ មានទីផ្សារសម្រាប់លក់ដោះដូរផលិតផលក្នុងស្រុក។

- ○ សម្រាប់ប្រជាកសិករមួយចំនួន បើទោះជាមានទីផ្សារសម្រាប់លក់ផលិតផលកសិកម្មក៏ដោយ ពួកគេនៅតែមិនអាចកំណត់តម្លៃផលិតផលកសិកម្មរបស់ខ្លួនបាននៅឡើយទេ។ ប្រជាកសិករ៧៥ភាគរយ ឆ្លើយថាឈ្មួញកណ្ដាលនៅតែដើរតួនាទីសំខាន់ក្នុងការកំណត់តម្លៃទៅលើផលិតផលកសិកម្ម នៅពេលចចារទិញលក់ម្ដងៗ។ ដោយឡែកប្រជាកសិករត្រឹមតែ១៦.៣ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពកំណត់តម្លៃកសិផលរបស់ខ្លួន។
- ○ ស្រដៀងគ្នានេះ ប្រជាកសិករ២.៩ភាគរយកំពុងអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម។ គម្រូទីផ្សារតាមបែបកិច្ចសន្យាលើផលិតកម្មកសិកម្មហាក់មានការប្រើប្រាស់ និងជម្រុញជាខ្លាំងនៅក្នុងអំឡុងនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩។
- ○ ស្របពេលនឹងការបាត់បង់ ឬថយចុះនៃការប្រាក់ចំណូលរបស់ប្រជាកសិករ ការចំណាយប្រចាំថ្ងៃរបស់ពួកគាត់មានការកើនឡើង ដោយសារការកើនឡើងនៃតម្លៃទំនិញ(រួមមានអាហារ ម៉ាស សាប៊ូ អាល់កុល ជាដើម) ទោះបីជាមានសេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារចំពោះកិច្ចការគ្រប់គ្រងផ្គត់ផ្គង់ និងតម្លៃទំនិញយុទ្ធសាស្ត្រក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ យ៉ាងណាក៏ដោយ។

- ▪ ផលប៉ះពាល់ និងភាពប្រឈមទៅនឹងកង្វះស្បៀងអាហារ និងទឹករបស់ប្រជាកសិករ៖
  - ○ ប្រជាកសិករចំនួន៥៩.៨ភាគរយ មិនមានអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ក្នុងក្រុមគ្រួសារនាពេលបច្ចុប្បន្ន ឬអំឡុងពេលនៃកិច្ចសម្ភាសន៍នោះទេ។ ប្រជាកសិករ៣៤ភាគរយ ឆ្លើយថាពួកគេគ្មានអាហារបម្រុងទុកទេ ប្រសិនបើស្ថានភាពនៃការវិបត្តិនៅបន្តមាន។
  - ○ ប្រជាកសិករ១៨.៣ភាគរយ ប្រាប់ថាពួកគេមានអាហារបម្រុងទុកក្នុងផ្ទះដែលអាចផ្គត់ផ្គង់គ្រួសាររបស់ពួកគេតិចជាងមួយខែ។ រីឯ២២ភាគរយផ្សេងទៀតមានលទ្ធភាពបម្រុងអាហារទុកលើសពី៥ខែ។
  - ○ ប្រជាកសិករ៥៧នាក់ (៥៥.៩ភាគរយ) មិនមានទឹកគ្រប់គ្រាន់សម្រាប់ទទួលទាន ដាំដំណាំ និងប្រើប្រាស់ទូទៅនៅក្នុងគ្រួសារ។
- ▪ ការគាំទ្រ និងឧបត្ថម្ភពីរាជរដ្ឋាភិបាល៖
  - ○ ប្រជាកសិករភាគរយច្រើនលើសលប់(៩៥.១ភាគរយ) មិនទទួលបានការគាំទ្រ ឬឧបត្ថម្ភនានាពីរាជរដ្ឋាភិបាលទេគិតមកត្រឹមថ្ងៃសម្ភាសន៍ក៏ដោយ (ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០)។ មានតែប្រជាកសិករ ចំនួន៤.៩ភាគរយ ប្រាប់ថាពួកគេធ្លាប់បានទទួលបានសម្ភារៈការពារខ្លួន និងអាហារមួយចំនួននៅអំឡុងពេលការរាតត្បាតពីជំងឺកូវីដ ១៩។

- សម្រាប់ការគាំទ្រ ឬ ឧបត្ថម្ភដោយឡែកផ្សេងទៀត ជាពិសេសកម្មវិធីឥណទានឧបត្ថម្ភការធ្វើកសិកម្មរបស់ប្រជាកសិករ តាមរយៈធានាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដែលមានទឹកប្រាក់សរុប ៥០លានដុល្លារ ជាមួយការប្រាក់ទាប ប្រជាកសិករដែលចូលរួមកិច្ចសម្ភាសន៍នេះមិនទទួលបានផលប្រយោជន៍ពីកម្មវិធីនេះនៅឡើយទេ បើគិតត្រឹមថ្ងៃនៃកិច្ចសម្ភាសន៍។
- ស្រដៀងគ្នានេះដែរ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ ១៩ ដែលបានដាក់ចុះឲ្យអនុវត្តនាពេលថ្មីៗនេះ (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២០) ហាក់មិនទាន់មានវិសាលភាពគ្រប់ដណ្តប់ទៅលើប្រជាកសិករដែលចូលរួមក្នុងកិច្ចសម្ភាសន៍នៅឡើយទេ។

- បញ្ហាបំណុល៖
  - ប្រជាកសិករ៧២.៨ភាគរយ ខ្ចីប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារ មុនពេលមានការផ្ទុះឡើងនៃមេរោគកូវីដ ១៩។ ពួកគេភាគច្រើនសុទ្ធសឹងកំពុងជំពាក់បំណុលពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬឯកទេស និងអ្នកចងការប្រាក់ឯកជន។ ប្រជាកសិករ២៩.៤ភាគរយប្រាប់ថាពួកគេ ខ្ចីបំណុលបន្ថែមដើម្បីផ្គត់ផ្គងគ្រួសារនៅអំឡុងពេលវិបត្តិពីមេរោគកូវីដ ១៩។ ប្រជាកសិករ១៨ភាគរយ ប្រាប់ថាបំណុលដែលខ្លួនបានខ្ចីបន្ថែម គឺប្រើប្រាស់ដើម្បីសងបំណុលដែលពួកគេមានតាំងពីពេលមុន។
  - ប្រជាកសិករចំនួន៤៨.៩ភាគរយ បានដាក់ពាក្យស្នើសុំពន្យាលពេលសងបំណុលត្រឡប់ទៅស្ថាប័នទាំងនោះ។
- បញ្ហាជម្លោះដីធ្លី និងការទន្ទ្រានដីធ្លី និងធនធានធម្មជាតិនៅអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩៖
  - ប្រជាកសិករ៦២.៥ភាគរយ ប្រាប់ថាការរំលោភដីធ្លី គម្រោងវិនិយោគឯកជនធំៗ បទល្មើស នេសាទ បទល្មើសព្រៃឈើ អាជីវកម្មរុករករ៉ែ ជាដើម នៅបន្តកើតឡើងនៅក្នុងសហគមន៍ដែលពួកគេកំពុងរស់នៅ។ ក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ១៩ ពុំមានករណីជម្លោះដីធ្លីរបស់សហគមន៍ណាមួយត្រូវបានរាយការណ៍ថាបានដោះស្រាយនោះទេ។
  - ប្រជាកសិករ២០.២ភាគរយ ថាមានករណីរំលោភបំពានថ្មីកើតឡើង។
  - សមាជិកសហគមន៍បានរាយការណ៍ថា សិទ្ធិក្នុងការជួបប្រជុំ និងការប្រមូលផ្តុំរបស់សហគមន៍ដើម្បីទាមទារ និងស្វែងរកដំណោះស្រាយដីធ្លី និងការលុបបំបាត់បទល្មើសធនធានធម្មជាតិ ត្រូវបានរឹតត្បិតយ៉ាងតឹងរឹង។
- ការការពារខ្លួន និងដំណោះស្រាយមួយចំនួនរបស់ប្រជាកសិករនាអំឡុងពេលនៃវិបត្តិ៖ ប្រជាកសិករមួយចំនួន បានបន្តអនុវត្តនូវការធ្វើកសិកម្មតាមបែបកៀត្របរិស្ថាន ហើយការអនុវត្តប្រព័ន្ធដាំដុះបែប

នេះ ធ្វើឲ្យពួកគេមានអាហារសម្រាប់ទទួលទានគ្រប់គ្រាន់។ ប្រជាកសិករមួយចំនួនទៀត បានបន្តចែករំលែកគ្រាប់ពូជដំណាំ ដែលពួកគេមិនចាំបាច់ចំណាយប្រាក់កាក់យកទៅដាំដុះដើម្បីជួយគ្នាទៅវិញទៅមក។

- តម្រូវការ អនុសាសន៍ និងសំណើរជូនរាជរដ្ឋាភិបាលៈ

<u>ជុំវិញបញ្ហាជំងឺកូវីដ ១៩</u>

- ស្នើរដ្ឋាភិបាលផ្តល់នូវថ្នាំវ៉ាក់សាំង និងបន្តផ្តល់សេវាថែទាំ និងព្យាបាលអ្នកជំងឺកូវីដ ១៩ ដោយមិនគិតថ្លៃ មានគុណភាព និងយកចិត្តទុកដាក់។
- ស្នើរដ្ឋាភិបាលចេញសេចក្តីប្រកាសពន្យាពេលសងការប្រាក់និងធ្វើកិច្ចអន្តរាគមន៍ ដោយផ្ទាល់ជាមួយធនាគារពាណិជ្ជ ឬឯកទេស ស្ថាប័ន មីក្រូហិរញ្ញវត្ថុឯកជនក្នុងការអនុវត្តសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាកសិករខ្នាតតូច និងមធ្យមនៅអំឡុងពេលវិបត្តិនៃមេរោគកូវីដ ១៩។
- ស្នើរដ្ឋាភិបាលផ្តល់នូវជំនួយជាស្បៀងអាហារ និងឧបត្ថម្ភសម្ភារៈ ដូចជាសាប៊ូ ម៉ាស អាល់កុលដើម្បីគាំទ្រទៅដល់អ្នកក្រីក្រ ចាស់ជរា អ្នកគ្មានទីពឹង។
- ស្នើរអោយមានវិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងគ្រាអាសន្នដោយមានការចូលរួមពិគ្រោះយោបល់ជាមួប្រជាពលរដ្ឋ។

<u>ជុំវិញបញ្ហារួមរបស់សហគមន៍</u>

- ស្នើររដ្ឋាភិបាលឧបត្ថម្ភធន (ដី ទឹក ទុន) ដើម្បីជួយស្តារសេដ្ឋកិច្ចគ្រួសារ និងជីវភាពប្រជាកសិករខ្នាតតូច និងមធ្យម ក្នុងវិស័យកសិកម្មនៅកម្ពុជា។
- ត្រូវពន្លឿនការដោះស្រាយទំនាស់ដីធ្លី និងអនុវត្តការបែងចែកដីធ្លីទៅដល់ប្រជាកសិករខ្នាតតូច និងមធ្យមដោយមានទំហំសមរម្យ (ដោយការពិគ្រោះយោបល់ជាមួយកសិករខ្នាតតូច និងមធ្យម) ការកសាង និងពង្រីកវិសាលភាពប្រព័ន្ធធារាសាស្រ្តបន្ថែមទៀត (ស្រះទឹក អណ្តូង ស្តារស្រះ ឬប្រឡាយទឹក) និងការលើកទឹកចិត្តការប្រើប្រាស់ឧបករណ៍បុរាណដែលមិនតម្រូវឲ្យមានការចំណាយច្រើនទៅលើធាតុចូលកសិកម្ម និងការស្តារឡើងវិញនូវពូជបុរាណជាជំហ៊ានចាំបាច់សម្រាប់កាត់បន្ថយបញ្ហា វិបត្តិមួយចំនួននៅពេលអនាគតដើម្បីធានាឲ្យបាននូវអធិបតេយ្យស្បៀង សម្រាប់ប្រជាពលរដ្ឋទាំងនិងជួយរក្សាស្ថេរភាពស្បៀងអាហារនៅក្នុងគ្រួសារ និងវិស័យកសិកម្មនៅកម្ពុជា។

- អន្តរាគមន៍ការពារធនធានធម្មជាតិ និងពង្រឹងការអនុវត្តច្បាប់ ដោយបញ្ឈប់អ្នកមានមុខតំណែងពីការប្រើប្រាស់អំណាច ឬបក្សពួកនិយម ដែលគាបសង្កត់ប្រជាកសិករ គណៈកម្មការការពារព្រៃឈើសហគមន៍ និងសមាជិកសហគមន៍ជាដើម។ ទទូចឲ្យមានការកាត់បន្ថយអាត្រាការប្រាក់កម្ចី និងអនុវត្តការលើកលែងមួយចំនួនសម្រាប់ប្រជាកសិករដែលមានការខ្វះខាតខ្លាំង។
- ទទូចឲ្យមានការពិនិត្យទៅលើលក្ខខណ្ឌ នៃការផ្តល់ឥណទានរបស់ស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬឯកទេស ជាពិសេសសម្រាប់នីតិវិធីនៃការផ្តល់ប្រាក់ដល់ប្រជាកសិករខ្នាតតូច និងមធ្យម។
- ទទូចឲ្យមានការលើកស្ទួយវិស័យកសិកម្មតាមបែបក្សេត្របរិស្ថាន ជាពិសេសការចូលរួមដោយប្រជាកសិករខ្នាតតូច និងមធ្យម អាចនឹងចូលរួមកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋពេញកម្លាំង។ ប្រជាកសិករខ្នាតតូច និងមធ្យមនៅតែចូលរួមយ៉ាងសំខាន់ក្នុងការផលិតដើម្បីចិញ្ចឹមប្រជាពលរដ្ឋដទៃទៀតទូទាំងប្រទេស ដូចនេះលើកស្ទួយប្រជាកសិករ និងអ្នកស្រែជាភាពចាំបាច់ និងជាការស្តារជំនឿចិត្តចំពោះយុវជនជំនាន់ក្រោយទៅលើការពិចារណាការងារកសិកម្ម។

# ១. សេចក្តីផ្តើម

ការផ្ទុះឡើង និងការរីករាលដាលនៃជំងឺកូវីដ ១៩ បានឆក់យកអាយុជីវិតប្រជាជនជិត៧សែននាក់ គិតត្រឹមសប្តាហ៍ទីមួយនៃខែសីហា ឆ្នាំ២០២០។[1] ការរាតត្បាតនៃជំងឺកូវីដ ១៩ បង្កឲ្យមានវិបត្តិជាច្រើននៅទូទាំងសកលលោក។ វិសមភាពដែលបានចាក់ឫសគល់ជាយូរឆ្នាំមកហើយ បានរំលេចចេញជារូបរាងកាន់តែច្បាស់។ គម្លាតនៃវិសមភាពក៏នឹងពង្រីកបន្ថែមទៀតចេញពីវិបត្តិការរាតត្បាតនៃជំងឺកូវីដ ១៩។[2] វាក៏មិនមែនជាលើកទីមួយ ដែលប្រទេសជាច្រើននៅក្នុងសកលលោកជួបវិបត្តិ ជាពិសេសមកលើសុខាភិបាល សង្គម និងសេដ្ឋកិច្ចជាដើម។ វិបត្តិលើកនេះ បានឆ្លុះបញ្ចាំងជាថ្មីម្តងទៀតពីភាពផុយស្រួយ និងភាពងាយរងគ្រោះនានានៃប្រទេសជាច្រើនដែលកំពុងអនុវត្តគម្រូសេដ្ឋកិច្ចបច្ចុប្បន្ន "សេរីភាវូបនីយកម្មបែបថ្មី"។

ជាក់ស្តែងរហូតមកទល់ពេលបច្ចុប្បន្ននេះ មិនទាន់មានរបាយការណ៍ផ្លូវការណាមួយបង្ហាញពីការបាត់បង់ជីវិត ឬផលប៉ះពាល់ធ្ងន់ធ្ងរពីការរាតត្បាតនៃជំងឺកូវីដ ១៩ មកលើ វិស័យសុខាភិបាលសាធារណៈនៅក្នុងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ផលប៉ះពាល់ដែលស្តែងចេញពីវិបត្តិនានាដែលបណ្តាលពីមេរោគនេះមកលើសេដ្ឋកិច្ច សង្គមជាតិ និងប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ គឺមិនអាចបដិសេធបាននោះទេ។ ផលប៉ះពាល់ និងបញ្ហាប្រឈមមួយចំនួនដែលប្រទេសកម្ពុជាកំពុងជួបប្រទះ គឺមានភាពស្រដៀងគ្នាទៅនឹងប្រទេសជាច្រើននៅក្នុងសកលលោក។

វិធានជាច្រើនត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តជាបន្តបន្ទាប់ក្នុងន័យទប់ស្កាត់បង្ការការរីករាលដាលនៃជំងឺកូវីដ ១៩ ដោយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ។ វិធានមួយចំនួនបានផ្តល់ផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានមកលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមួយចំនួន។

ប្រជាពលរដ្ឋទូទៅរួមទាំងប្រជាកសិករខ្នាតតូច និងមធ្យម កម្មករ (កម្មករដែលបំពេញការងារនៅក្នុងវិស័យនៃសេដ្ឋកិច្ចក្នុងនិងក្រៅប្រព័ន្ធ) ព្រមទាំងប្រជាពលរដ្ឋមួយចំនួនទៀតដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើចំណូលដែលបានពីការប្រកបរបរចិញ្ចឹមជីវិត ពីមួយថ្ងៃទៅមួយថ្ងៃ ទទួលរងផលប៉ះពាល់ និងប្រឈមភាពងាយរងគ្រោះជាច្រើនដូចជា៖ បញ្ហាកង្វះស្បៀងអាហារ ទឹក ការបាត់បង់ប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិត

---

[1] "របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ ១៩ លេខ១៩៨" អង្គការសុខភាពពិភពលោកទទួលបាន របាយការណ៍ពីអាជ្ញាធរជាតិនៃប្រទេសសមាជិកនាម៉ោង ១០:០០ ស៊ីអ៊ីអេសធី ថ្ងៃទី៥ សីហា ឆ្នាំ២០២០។ https://www.who.int/docs/default-source/coronaviruse/situation-reports/20200805-covid-19-sitrep-198.pdf?sfvrsn=f99d1754_2

[2] "មេរោគកូរ៉ូណា vs. វិសមភាព" អត្ថបទវិភាគរបស់អង្គការសហប្រជាជាតិផ្តោតលើការអភិវឌ្ឍ https://feature.undp.org/coronavirus-vs-inequality/

បាត់បង់ទ្រព្យសម្បត្តិដោយសារ ពុំមានលទ្ធភាពសងបំណុលត្រឡប់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬម្ចាស់បំណុល[3] និងការពន្យារពេលចំពោះការទទួលបានយុត្តិធម៌ជាដើម។

របាយការណ៍នេះ បង្ហាញពីផលប៉ះពាល់ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសប្រជាកសិករនាអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ ១៩។ វិធាន និងយន្តកាការពារទប់ស្កាត់ ព្រមទាំងការឆ្លើយតបរបស់រាជរដ្ឋាភិបាលត្រូវបានត្រួតពិនិត្យ និងសិក្សាស្វែងយល់ពីប្រសិទ្ធភាពជាពិសេសការឆ្លើយតបជាលក្ខណៈប្រព័ន្ធដោយត្រូវបានបញ្ចូលផងដែរ។ របាយការណ៍នេះ ក៏បានដាក់បញ្ចូលនូវតម្រូវការ សំណូមពរ និងសំណើរជំនួសរបស់ប្រជាកសិករជូនដល់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ។

## ២. អំពីរបាយការណ៍

### ២.១. គោលបំណងការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នៃមេរោគកូវីដ ១៩ គឺជាគំនិតផ្តួចផ្តើមរបស់ សម្ព័ន្ធបងប្អូនស្រីរួមជាមួយបណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ និងកម្មវិធីផ្តោតលើលោកខាងត្បូង (Focus on the Global South)។ សម្រាប់របាយកាណ៍សិក្សាស្រាវជ្រាវស្តីពី **ស្វែងយល់ពីផលប៉ះពាល់នៃវិបត្តិមេរោគកូវីដ ១៩ មកលើប្រជាកសិករនៅក្នុងប្រទេសកម្ពុជា** ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងបណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍនៃសម្ព័ន្ធបងប្អូនស្រី កម្មវិធីផ្តោតទៅលើលោកខាងត្បូង និងតំណាងប្រជាកសិករពីសហគមន៍មូលដ្ឋានមួយចំនួន។

បន្ទាប់ពីមានការផ្ទុះឡើង និងការរាតត្បាតនៃជំងឺកូវីដ ១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានមួយចំនួនដែលក្នុងនោះរួមមាន៖ សេចក្តីជូនដំណឹងពីឈប់វិស្សមកាលមុនកាលកំណត់របស់សិស្សនិស្សិត[4] និងការផ្អាកដំណើរការនៃគ្រឹះស្ថានមួយចំនួនក្នុងវិស័យចម្រុះៗនៃសេដ្ឋកិច្ចជាបន្តបន្ទាប់។ តាមរយៈការអង្កេតប្រជាពលរដ្ឋទូទៅមានការភ័យខ្លាចចំពោះការបាត់បង់អាយុជីវិត ឬសមាជិកគ្រួសាររបស់ពួកគេ ដោយសារការរាតត្បាតនៃជំងឺកូវីដ ១៩ គឺចាប់ ពីខែមករារហូតដល់ខែមេសា ឆ្នាំ២០២០ ស្របពេលនៃការវិលត្រឡប់យ៉ាងគំហុករបស់ប្រជាពលរដ្ឋជាច្រើនដែលធ្វើការនៅក្រៅប្រទេសមកស្រុកកំណើតវិញជាដើម។

---

[3] ពលរដ្ឋបារម្ភខ្លាចគ្រឹះស្ថានឥណទានរឹបអូសទ្រព្យបញ្ចាំជាងបារម្ភអំពីវីរុសកូរ៉ូណាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ https://khmer.voanews.com/a/families-fear-banks-more-than-virus-as-loans-loom-over-their-heads/5421925.html

[4] សេចក្តីប្រកាសព័ត៌មានស្តីពីការអនុវត្តវិស្សមកាលតូច មិនមានកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ និងឯកជននៅរាជធានីភ្នំពេញ និងក្រុងសៀមរាបចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ក្នុងបរិបទនៃការ រីករាលដាលនៃជំងឺកូវីដ១៩។

ដូចនេះការចុះអង្កេតបឋមដើម្បីសិក្សាស្វែងយល់ពីស្ថានភាពរបស់ប្រជាកសិករ ដែលរស់នៅក្នុងតំបន់មូលដ្ឋានមួយចំនួននៅខេត្តចំនួនបីរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបងក៏ត្រូវបានធ្វើឡើង។ ជាលទ្ធផល ក្រុមការងារបានចងក្រងនូវបញ្ហាប្រឈមមួយចំនួនរបស់ប្រជាពលរដ្ឋជាពិសេសប្រជាកសិករ ប្រជានេសាទ និងអាជីវករលក់ដូរនៅក្នុងផ្សារក្នុងស្រុកភូមិមួយចំនួន នៅក្នុងខេត្តទាំងនោះ ជារបាយការណ៍ពីការសិក្សាបឋមត្រូវបានប្រើប្រាស់នៅក្នុងស្ថាប័ន។

បញ្ហាចម្បងដែលប្រជាកសិករ និងប្រជានេសាទមួយចំនួនជួបប្រទះនាពេលនោះគឺ ជុំវិញក្ដីបារម្ភ និងភាពភ័យខ្លាចបាត់បង់ជីវិត និងការឆ្លងមេរោគកូវីដ ១៩។ យ៉ាងហោចណាស់ប្រជាពលរដ្ឋមួយគ្រួសារ មិនមានអាហារទទួលទានដោយសារការប្រកបរបរលក់ការ៉េមរបស់គាត់ផ្អាកដំណើរការ។ ស្រដៀងគ្នានេះដែរ ប្រជាពលរដ្ឋមួយចំនួនទៀត បង្ហាញពីក្ដីបារម្ភរបស់ពួកគេជុំវិញបញ្ហាកង្វះស្បៀងអាហារ ទឹក(បណ្ដាលពីភាពរាំងស្ងួត) និងភាពភ័យខ្លាចចំពោះការរីវវដ្ដកាន់តែអាក្រក់នៃមេរោគកូវីដ ១៩ នៅក្នុងសហគមន៍ពួកគេ។

ក្រុមការងារនៃបណ្ដាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ និងកម្មវិធីផ្ដោតលើលោកខាងត្បូង ក៏បានបន្តតាមដានព័ត៌មានជាមួយប្រជាពលរដ្ឋដែលស្ថាប័នទាំងពីរនេះធ្វើការជាមួយដោយផ្ទាល់ផងដែរ។ ដោយហេតុនេះហើយ ការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នេះ ក៏ត្រូវបានធ្វើឡើងដើម្បីធ្វើការស្វែងយល់ឲ្យកាន់តែស៊ីជម្រៅទៅលើស្ថានភាពរបស់ប្រជាពលរដ្ឋជាពិសេសជាមួយប្រជាកសិករដែលរស់នៅក្នុងសហគមន៍មូលដ្ឋាននៃបណ្ដាខេត្តមួយចំនួន។

**ការសិក្សាស្រាវជ្រាវនេះធ្វើឡើង ក្នុងគោលបំណង៖**

១. សិក្សាស្វែងយល់ពីផលប៉ះពាល់នៃវិបត្តិពីមេរោគកូវីដ ១៩ មកលើប្រជាកសិករ និងតម្រូវការពួកគេក្នុងអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ ១៩ និង

២. លើកឡើងនូវវិធីសាស្ត្រ ជម្រើសជំនួស ឬសំណើរនានាទាក់ទងទៅនឹងដំណើរការនៃប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធសាធារណៈពីសំណាក់ប្រជាកសិករដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់។

## ២.២. វិធីសាស្ត្រ

ការសិក្សាស្រាវជ្រាវធ្វើឡើងជាទម្រង់បែបបរិមាណ និងគុណភាព។ កិច្ចសម្ភាសន៍ ធ្វើឡើងតាមរយៈការជួបសម្ភាសន៍ដោយផ្ទាល់ និងការទំនាក់ទំនងតាមប្រព័ន្ធទូរស័ព្ទ។ ការសម្ភាសន៍មានជាលក្ខណៈបុគ្គលគ្រួសារ តំណាងសហគមន៍ និងក្រុមពិភាក្សា ហើយចាប់ផ្ដើមពីថ្ងៃទី១០ ខែឧសភា និងបញ្ចប់នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០។

ឯកសារ និងទិន្នន័យពាក់ព័ន្ធមួយចំនួនត្រូវបានត្រួតពិនិត្យ និងវិភាគយ៉ាងយកចិត្តទុកដាក់មុនពេលបញ្ចូលទៅក្នុងរបាយការណ៍នេះ។

តំណាងសហគមន៍ និងប្រជាកសិករចំនួន៩នាក់ ចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវទាំងមូល ចាប់ពីការពិគ្រោះ បង្កើត និងសាកល្បងកម្រងសំណួរ ចុះសម្ភាស និងពិគ្រោះយោបល់ទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ។ និស្សិតនៃមហាវិទ្យាល័យមួយចំនួនក្នុងរាជធានីភ្នំពេញ បានស្ម័គ្រចិត្តបញ្ចូលទិន្នន័យ។

### ២.៣. កម្រិតភាព

ដោយសារធនធានមានកម្រិត ក្រុមការងារស្រាវជ្រាវ សម្រេចចិត្តផ្តល់អាទិភាពទៅលើតំបន់ភូមិសាស្ត្រនៃខេត្តមួយចំនួនដើម្បីធ្វើការសិក្សា។ ក្នុងនោះដែរ ខេត្តចំនួនពីរគឺខេត្តបាត់ដំបង និងកំពង់ឆ្នាំងដែលស្ថិតនៅក្នុងការសិក្សានេះ មានចំនួនអ្នកចូលរួមច្រើនជាងខេត្តដទៃដោយសារខេត្តទាំងពីរនេះ មានសមាជិកសហគមន៍ពីចម្រុះវិស័យ។

ការសិក្សាស្រាវជ្រាវធ្វើឡើងជាមួយប្រជាពលរដ្ឋចំនួន ១០៤នាក់ ដោយផ្តោតទៅលើបទពិសោធន៍ និងផលប៉ះពាល់នានាមកលើពួកគេដោយផ្ទាល់។ ការសិក្សានេះ និងមិនបានគ្របដណ្តប់ទូលំទូលាយនូវបញ្ហាប្រជាពលរដ្ឋដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ដោយសារកម្រិតភាពនៃក្រុមការងារសិក្សាស្រាវជ្រាវ។ ដូចនេះ ដោយសារប្រជាកសិករចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះមកពីចម្រុះវិស័យ ជាមួយនឹងកម្រិតភាពរបស់ពួកយើងរបកគំហើញពីការសិក្សាស្រាវជ្រាវនេះ គឺគ្របដណ្តប់នូវបញ្ហាមួយចំនួនដែលសំខាន់ និងចម្បងៗដែលប្រជាកសិករភាគច្រើនជួបប្រទះ។

ការសិក្សានេះ មិនបានគ្រប់ដណ្តប់ ឬបញ្ចូលនូវទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន ឬ ស្ថាប័នពាក់ព័ន្ធមួយចំនួននោះទេដោយសារតែកម្រិតភាពនៃពេលវេលា និងធនធានរបស់ក្រុមការងារសិក្សាស្រាវជ្រាវ។

សូមបញ្ជាក់ថា ដើម្បីរក្សាសុវត្ថិភាព និងព័ត៌មានឯកជននៃប្រជាកសិករដែលចូលរួម ឈ្មោះរបស់ពួកគេនៅក្នុងរបាយការណ៍ និងត្រូវបានតាងជំនួសដោយអក្សរកាត់ ឬ ឈ្មោះប្រឌិត។
លទ្ធផលនៅក្នុងរបាយការណ៍សិក្សាស្រាវជ្រាវនេះ និងមិនតំណាងឲ្យស្ថានភាព ឬ បទពិសោធន៍របស់ប្រជាពលរដ្ឋពិសេសប្រជាកសិករមូលដ្ឋានទូទាំងប្រទេសនោះទេ។

## ៣. ព័ត៌មានទូទៅរបស់ប្រជាកសិករ




*ចំនួនអ្នកឆ្លើយ៖ ១០៤នាក់*

ប្រជាពលរដ្ឋចូលរួមក្នុងកិច្ចសម្ភាសន៍មានចំនួនសរុប១០៤នាក់ មកពីខេត្តចំនួន១៧ ស្រុកចំនួន៥០ ឃុំចំនួន៧៣ និងភូមិចំនួន៨១ ហើយភាគច្រើនលើសលុប គឺជាកិសករ។

ប្រជាពលរដ្ឋ ចូលរួមក្នុងកិច្ចសម្ភាសន៍ មាន ប្រជាកសិករចូលរួមក្នុងការសិក្សា ៥៦.៩ ភាគរយ គឺជាបុរស ហើយ ៤៣.១ភាគរយទៀតគឺជាស្ត្រី។ ជាងពាក់កណ្តាលនៃអ្នកចូលរួម មានអាយុចន្លោះពី៤០ឆ្នាំ ដល់៥៩ឆ្នាំ និងប្រមាណ៣០ភាគរយផ្សេងទៀតមានអាយុលើសពី៦០ឆ្នាំ។ រីឯភាគរយដែលតិចជាងគេនៃអ្នកចូលរួមមានអាយុចន្លោះ១៨ ដល់២៤ឆ្នាំ។




# ៤. និន្នាភាពទូទៅជុំវិញការរាតត្បាត និងវិបត្តិនានាដែលបណ្តាលពីជំងឺកូវីដ១៩

## ៤.១. និន្នាភាពទូទៅជុំវិញការផ្ទុះឡើង និងការរាតត្បាតនៃជំងឺកូវីដ ១៩

មេរោគកូវីដ ១៩ បានរីករាលដាលពាសពេញពិភពលោកចាប់តាំងពីដើមឆ្នាំ២០២០ រហូតមកទល់ពេលបច្ចុប្បន្ន។ គិតមកត្រឹមខែសីហា ឆ្នាំ២០២០ ជំងឺកូវីដ ១៩ បានសម្លាប់មនុស្សជិត៧សែននាក់។[5] មេរោគកូវីដ ១៩ បានបណ្តាលឲ្យមានវិបត្តិជាច្រើន ហើយក្នុងចំណោមវិបត្តិទាំងនោះ ប្រជាជនរាប់សែននាក់បានបាត់បង់ការងារ និងប្រាក់ចំណូល និងប្រឈមនឹងវិបត្តិកង្វះស្បៀងអាហារជាដើម។ អំពើហិង្សាមកលើស្ត្រីត្រូវបានកើនឡើងផងដែរនៅក្នុងប្រទេសមួយចំនួន។[6]

កម្ពុជាបានរកឃើញអ្នកមានផ្ទុកជំងឺកូវីដ ១៩ ដំបូងបង្អស់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។[7] ចំនួនអ្នកឆ្លងមេរោគកូវីដ ១៩ មានការកើនឡើងចាប់តាំងពីខែមករា រហូតមកដល់សប្តាហ៍ទីពីរនៃខែសីហា ឆ្នាំ២០២០។ ចំនួនអ្នកមានផ្ទុកជំងឺកូវីដ១៩ មានចំនួន ២៧៣នាក់(ស្រី៥៤នាក់) អ្នកជំងឺជាសះចំនួន២២៩នាក់

---

[5] "របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ ១៩ លេខ ១៩៨" អង្គការសុខភាពពិភពលោកទទួលបាន របាយការណ៍ពីអាជ្ញាធរជាតិនៃប្រទេសសមាជិកនាម៉ោង ១០:០០ ស៊ីអ៊ីអេសធី ថ្ងៃទី៥ សីហា ឆ្នាំ២០២០។ https://www.who.int/docs/default-source/coronaviruse/situation-reports/20200805-covid-19-sitrep-198.pdf?sfvrsn=f99d1754_2

[6] Explainer – how COVID-19 Impacts women and girls, UNWomen https://interactive.unwomen.org/multimedia/explainer/covid19/en/index.html?gclid=EAIaIQobChMIiJDtyt626wIVkXZgCh1WmQSVEAAYASAAEgJBr_D_BwE

[7] វីអូអេ កម្ពុជាប្រកាសករណីទី១នៃវីរុសកូរ៉ូណាដែលរកឃើញលើជនជាតិចិនម្នាក់នៅខេត្តព្រះសីហនុ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។https://khmer.voanews.com/a/first-case-of-coronavirus-confirmed-in-Cambodia/5261841.html

(ស្រី៤៦) និងកំពុងសម្រាកទទួលការព្យាបាលនៅមន្ទីរពេទ្យរដ្ឋចំនួន៤៤នាក់។[8] បើទោះបីជាចំនួននៃអ្នកមានជំងឺកូវីដ ១៩ មានចំនួនតិចប្រៀបធៀបជាមួយនឹងប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ[9] ក៏ប៉ុន្តែការផ្ទុះឡើង និងការរីករាលនៃជំងឺកូវីដ ១៩ ជាបន្តបន្ទាប់ បានធ្វើឲ្យប្រជាជនទូទៅ ភាគច្រើនមានភាពភ័យខ្លាច និងតក់ស្លុតជាខ្លាំង។



*ការធ្លាក់ចុះចំនួនភ្ញៀវទេសចរណ៍នៅតាមតំបន់ទេសចរណ៍ធម្មជាតិមួយចំនួននៅក្នុងប្រទេសកម្ពុជា។ (រមណីយដ្ឋានទឹកជ្រោះច្រកល្មៀង ខេត្តពោធិ៍សាត់)*

វិធានការ ការពារសុខភាព និងអាយុជីវិតដែលប្រជាពលរដ្ឋមួយចំនួន បានសម្រេចចិត្តចូលរួមមានដូចជា៖ ការផ្អាកដំណើរការមុខរបររបស់ខ្លួន ការប្រមូលទិញ ឬស្តុកទុកស្បៀងអាហារសម្រាប់ទទួលទានក្នុងចំណោមប្រជាជនដែលមានលទ្ធភាព និងរស់នៅតាមទីប្រជុំជន ឬទីក្រុង ការប្រមូលសាច់ញាតិដែលកំពុងប្រកបរបរ ឬសិក្សានៅបណ្តាខេត្ត និងទីក្រុងមួយចំនួនត្រឡប់ទៅជួបជុំគ្រួសារ ឬមកស្រុកកំណើតវិញជា

[8] សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលស្តីពីមានករណីជាសះស្បើយ ០៤នាក់ និងមិនមានករណីវិជ្ជមានវីរុសកូវីដ ១៩ ថ្មី នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០។ ចុះថ្ងៃសៅរ៍ ទី១៥ ខែសីហា ឆ្នាំ២០២០ វេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

[9] Coronavirus disease 2019 (COVID-19) Situation Report – 83. Data as received by WHI from national authorities by 10:00 CET, 12 April 2020. https://www.who.int/docs/default-source/coronaviruse/situation-reports/20200412-sitrep-83-covid-19.pdf?sfvrsn=697ce98d_4

ដើម។ ភាពភ័យខ្លាច និងការព្រួយបារម្ភដ៏ខ្លាំងក្លារបស់ប្រជាពលរដ្ឋទូទៅ កើតឡើងពីដើមខែមករាហូតដល់ដើមខែមេសា ឆ្នាំ២០២០។[10] តាមរយៈការអង្កេតនាដំណាក់ការដំបូង ជាពិសេសមុនការចាត់វិធានការហាមប្រាមការធ្វើដំណើរឆ្លងស្រុកខេត្តទូទាំងប្រទេស ផ្សារនៅក្នុងតំបន់មូលដ្ឋានមួយចំនួន នៅក្នុងខេត្តជាប់ព្រំដែនសំខាន់ត្រូវបានផ្អាកដំណើរការ។

ស្របជាមួយគ្នានេះដែរ ក៏មានការឡើងតម្លៃទំនិញ សម្ភារៈសម្រាប់ការពារខ្លួន (ដូចជាម៉ាស ជែល ឬអាល់កុលសម្រាប់លាងដៃ និងក្រម៉ាជាដើម) និងស្បៀងអាហារ។ ម៉ាសដែលធ្លាប់មានតម្លៃទាប (ដោយម៉ាសពីរមានតម្លៃ ៥០០រៀលមុនពេលមានការផ្ទុះឡើងនៃមេរោគកូវីដ ១៩) ត្រូវបានលក់ក្នុងតម្លៃយ៉ាងថ្លៃដោយម៉ាសមួយត្រូវបានលក់ពីចន្លោះតម្លៃ២០០០រៀល ទៅ ៤០០០ រៀល។ ការលក់ក្នុងតម្លៃនេះ បន្ថែមបន្ទុកសម្រាប់ប្រជាពលរដ្ឋទូទៅជាពិសេសប្រជាពលរដ្ឋក្រីក្រដែលកំពុងប្រឈមមុខ និងទទួលរងនូវផលប៉ះពាល់ជាច្រើនដែលមានស្រាប់ពីវិបត្តិនៃការរាតត្បាតពីជំងឺកូវីដ ១៩។

បើទោះជាមានក្តីបារម្ភជាច្រើនយ៉ាងណាក្តីពីសំណាក់ប្រជាកសិករមួយចំនួន ក៏ប៉ុន្តែប្រជាកសិករមួយចំនួនទៀត ដែលកំពុងរស់នៅក្នុងតំបន់ដាច់ស្រយាល បានបន្តប្រកបរបររបស់ពួកគេធម្មតា។[11] បញ្ហាក្រពះ និងលទ្ធភាពនៃការសងបំណុលត្រឡប់ទៅកាន់ស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬម្ចាស់បំណុលជាកត្តាចម្បងសម្រាប់ពួកគេ បើទោះបីជាពួកគេមានការបារម្ភចំពោះហានិភ័យនានាដែលអាចកើតឡើងដោយសារការរាតត្បាតនៃជំងឺកូវីដ ១៩។

## ៤.២. វិធាន និងយន្តការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ និងការឆ្លើយតបទៅនឹងវិបត្តិនានាដែលជំងឺរាតត្បាតនេះបង្កឡើង

រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធបានដាក់ចេញនូវវិធានមួយចំនួនក្នុងន័យទប់ស្កាត់បង្ការការរីករាលដាលនៃជំងឺកូវីដ ១៩ និងចាត់វិធានការឆ្លើយតបទៅនឹងវិបត្តិនេះនៅទូទាំងប្រទេស។ វិធានទាំងនោះមានដូចជា៖ សេចក្តីជូនដំណឹងពីការឈប់វិស្សមកាលមុនកាលកំណត់របស់សិស្សនិស្សិត[12] ការប្រកាសឲ្យផ្អាក

[10] ការអង្កេតនេះ ត្រូវបានធ្វើឡើងតាមរយៈការប្រមូល និងតាមដានព័ត៌មានពីការវិវឌ្ឍនានា ទាំងសេចក្តីជូនរបស់រាជរដ្ឋាភិបាល ការប្រព្រឹត្តិទៅរបស់ប្រជាពលរដ្ឋនៅតាមទីសាធារណៈ និងការធ្វើបច្ចុប្បន្នភាពនៃស្ថានភាពជាមួយប្រជាពលរដ្ឋរស់នៅក្នុងខេត្តមួយចំនួន។

[11] របាយការណ៍ចុះសក្សាអង្កេតបឋមទៅខេត្តចំនួនបីដូចជាបាត់ដំបង កំពង់ឆ្នាំង និងបន្ទាយមានជ័យ។ សូមបញ្ជាក់ថារបាយការនេះ មិនត្រូវបានបោះពុម្ពដើម្បីផ្សព្វផ្សាយជាសាធារណៈនោះទេ។

[12] សេចក្តីប្រកាសព័ត៌មានស្តីពីការអនុវត្តវិស្សមកាលតូច មិនមានកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ និងឯកជននៅរាជធានីភ្នំពេញ និងក្រុងសៀមរាបចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ក្នុងបរិបទនៃការ រីករាលដាលនៃជំងឺកូវីដ១៩។

ដំណើរជាបណ្ដោះអាសន្ននៃក្លឹបកំសាន្ដ(ខារ៉ាអូខេ រង្គសាល ឌីស្កូតែក)[13] សណ្ឋាគារ ផ្ទះសំណាក់ កម្រិតការជួបជុំ និងការប្រមូលផ្ដុំជាសាធារណៈ[14] រឹតបណ្ដឹងការធ្វើដំណើរឆ្លងស្រុកខេត្តនានាទូទាំងប្រទេស[15] ការលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ កម្មករនិយោជិតនាឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិ២០២០[16] ការបិទដំណើរការច្រកចេញចូលអន្តរជាតិជាបណ្ដោះអាសន្ន[17] និងការធ្វើចត្តាឡីស័កសម្រាប់ប្រជាពលរដ្ឋដែលវិលត្រឡប់ពីបរទេស[18] និងប្រជាពលរដ្ឋដែលធ្វើដំណើរឆ្លងស្រុកខេត្តនាអំឡុងពេលហាមប្រាម[19]ជាដើម។ល។ ការផ្សព្វផ្សាយពីវិធីបង្ការ ការការពារខ្លួនពីការឆ្លង និងការអនុវត្តវិធានមួយចំនួន ពិសេសការរឹតត្បិតការជួបជុំសាធារណៈ និងការប្រារព្ធកម្មវិធីសាសនា ឬ សង្គមត្រូវបានអនុវត្តដោយអាជ្ញាធរមូលដ្ឋាន។

រាជរដ្ឋាភិបាល ក៏បានកំណត់ជ្រើសរើសទីតាំងមួយចំនួន សម្រាប់ធ្វើការចាត់វិធានការតាមដាន និងព្យាបាលប្រជាពលរដ្ឋដែលមានផ្ទុកមេរោគកូវីដ ១៩។ វិទ្យាស្ថានប៉ាស្ទ័រ គឺជាកន្លែងសម្រាប់ធ្វើតេស្តរកមេរោគ។ សំណាកនៃប្រជាពលរដ្ឋដែលសង្ស័យថាមានជំងឺ កូវីដ ១៩ ត្រូវបានបញ្ជូនពីមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត និងមន្ទីរពេទ្យសាធារណៈមួយចំនួនទៀត។ សណ្ឋាគារឯកជន អាគារសាលារៀនរដ្ឋ និងមន្ទី

---

[13] ក្រសួងទេសចរណ៍លេខ ១២៩ សជណអរហ ចុះថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័កពស ២៥៦៣ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ ស្ដីពីការបិទ KTV ក្លឹបកំសាន្ដ (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក) នៅគ្រប់រាជធានីខេត្តជាបណ្ដោះអាសន្នចាប់ពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ រហូតដល់មានការជូនដំណឹងជាថ្មី។

[14] រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ លេខ ០០៣ សជន សេចក្ដីណែនាំ ស្ដីពីការផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០។

[15] បទបញ្ជារបស់រាជរដ្ឋាភិបាលស្ដីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេសក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩។ https://www.kohkong.gov.kh/2020/41943/

[16] អនុក្រឹត្យស្ដីពីការលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករនៅថ្ងៃទី១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នាំ២០២០។ https://pressocm.gov.kh/archives/65579
https://www.moeys.gov.kh/index.php/kh/laws-and-legislations/sub-decree/sd20-50.html#.X0jJey2B1QI

[17] រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ លេខ ៩១៦ សជណ ស្ដីពីការផ្អាកជាបណ្ដោះអាសន្ននូវការធ្វើដំណើរចេញពីប្រទេសរបស់ប្រជាពលរដ្ឋកម្ពុជា ទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម និងការធ្វើដំណើរចូលព្រះរាជាណាចក្រកម្ពុជារបស់ប្រជាពលរដ្ឋវៀតណាម។ ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០។

[18] ក្រសួងមហាផ្ទៃ លេខ ១០០៧ សជណ ស្ដីពីវិធានការគ្រប់គ្រងបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ។ ថ្ងៃសុក្រ ៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០

[19] ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លេខ ០៥៦/២០ កប/សណន.ខ.ល សេចក្ដីណែនាំស្ដីពីវិធានការចត្តាឡីស័កចំពោះកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថានដែលបានឈប់សម្រាកក្នុងអំឡុងពេលបុណ្យចូលឆ្នាំ និងចូលបម្រើការងារវិញ ចុះថ្ងៃសុក្រ ១០រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០២០។

ពេទ្យសាធារណៈមួយចំនួន បានត្រៀមជាស្រេចសម្រាប់ដាក់អ្នកសង្ស័យ និងប្រើប្រាស់សម្រាប់ព្យាបាលអ្នកជំងឺកូវីដ ១៩។

ក្រៅពីវិធានខាងលើ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវយន្តការមួយចំនួនក្នុងន័យ ជួយអន្តរាគមន៍លើវិស័យ និងប្រជាពលរដ្ឋដែលងាយរងគ្រោះ។ យន្តការទាំងនោះមានដូចជា៖ ការអនុគ្រោះពន្ធ[20][21] ការអនុញ្ញាតឲ្យមិនបង់ប្រាក់ភាគទានធានារ៉ាប់រងហានិភ័យការងារ និងថែទាំសុខភាព ការផ្ដល់ភាពអនុគ្រោះលើលក្ខខណ្ឌឥណទាន (Credit relief)[22] ការផ្ដល់ប្រាក់ឧបត្ថម្ភរយៈពេល ២ខែសម្រាប់កម្មករ បុគ្គលិកក្នុងវិស័យការងារ និងទេសចរណ៍[23] ការរៀបចំហិរញ្ញប្បទានពិសេសដើម្បីជួយស្ដារលទ្ធភាព និងលើកកម្ពស់អាជីវកម្មរបស់សហគ្រាសធុនតូច និងមធ្យម[24] ការរៀបចំវគ្គបណ្ដុះបណ្ដាលជំនាញ និងការរៀបចំគម្រោងហិរញ្ញប្បទានសម្រាប់ទុនបង្វិលដើម្បីបំពេញតម្រូវការរបស់រោងចក្រ សហគ្រាស[25] ការផ្ដល់ឥណទានគាំទ្រដល់សិប្បកម្ម សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកែច្នៃផលិតផលកសិកម្ម វិស័យកសិឧស្សាហកម្ម និងវិស័យកសិកម្មតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងកម្មវិធីហិរញ្ញប្បទានដែលមានទឹកប្រាក់ចំនួន៥០លានដុល្លារដើម្បីផ្ដល់ឥណទានមានការប្រាក់ទាប[26] ជាដើម។ល។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ ១៩ ដែលជាកម្មវិធីជំនួយសង្គមថ្មីមួយ ក៏ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលនៅនាសប្ដាហ៍ទីបីនៃខែមិថុនា ឆ្នាំ ២០២០។ កម្មវិធីនេះផ្ដល់ប្រាក់ឧបត្ថម្ភប្រចាំខែដល់គ្រួសារក្រីក្រដែលមានប័ណ្ណសមធម៌។[27]

---

[20] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០៧ សហវ សេចក្ដីជូនដំណឹងស្ដីពីការបញ្ឈប់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនកាស៊ីណូជាបណ្ដោះអាសន្ន និងការលើកលែងការបង់ពន្ធពីការតព្វកិច្ចចំណូលប្រចាំខែ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០

[21] https://www.mef.gov.kh/measures-of-tax.html

[22] https://drive.google.com/file/d/1ZhbKO93V7XIm1CnCbaG5_jUmNE4W0PHl/view

[23] https://www.mef.gov.kh/measures-of-tax.html

[24] https://www.mef.gov.kh/pr-launch-20200403.html

[25] https://drive.google.com/file/d/1ZhbKO93V7XIm1CnCbaG5_jUmNE4W0PHl/view

[26] https://dap-news.com/national/2020/03/18/41661/

[27] សម្រង់ប្រសាសន៍សម្ដេចតេជោ ហ៊ុន សែន ពីធីប្រកាសដាក់ឲ្យដំណើរការជាផ្លូវការ "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ ១៩"។ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ អត្ថបទនេះដកស្រង់ចេញពីគេហទំព័រ កម្ពុជាទស្សនៈថ្មី។

## ៥. បទពិសោធពីការទទួលបានព័ត៌មានអំពីវិធាន យន្តការទប់ស្កាត់ និងការដោះស្រាយ

### ៥.១. បទពិសោធ និងការទទួលបានព័ត៌មាននានារបស់ប្រជាកសិករ

ប្រជាកសិករភាគច្រើនលើសលុប ឆ្លើយថាពួកគេទទួលបានព័ត៌មានទូទៅជុំវិញការបង្ការ ការការពារខ្លួន រោគសញ្ញា និងចំនួនអ្នកមានជំងឺកូវីដ ១៩ ជារៀងរាល់ថ្ងៃ តាមរយៈសេចក្តីប្រកាសនានារបស់ក្រសួងសុខាភិបាល។




*ការផ្សព្វផ្សាយព័ត៌មានក្នុងសហគមន៍*

ប្រជាកសិករចំនួន៤២.៧ភាគរយ ថាពួកគេមិនទទួលបានព័ត៌មានជុំវិញថ្នាំបង្ការ ការព្យាបាល ការធ្វើតេស្តរកមេរោគកូវីដ ១៩ ព័ត៌មានពីទីកន្លែងសម្រាប់ពិនិត្យ និងទទួលការព្យាបាលនៅឡើយទេ។

២ភាគ៣នៃប្រជាកសិករ ប្រាប់ថាពួកគេមិនទាន់បានទទួលព័ត៌មានពីការគាំទ្រផ្សេងៗ (ការឧបត្ថម្ភអាហារ ឧបត្ថម្ភធន សម្ភារៈសម្រាប់ការពារខ្លួន ជាដើម។ល។) ចំពោះប្រជាពលរដ្ឋទូទៅ ពីសំណាក់រាជរដ្ឋាភិបាល។

ប្រជាកសិករ ៨៧ភាគរយ ថាដឹងពីសរាចរ និងសេចក្តីប្រកាសមួយចំនួនរបស់រាជរដ្ឋាភិបាលទៅលើការហាមប្រាមការធ្វើដំណើរឆ្លងស្រុក និងខេត្តទូទាំងប្រទេសនាអំឡុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិឆ្នាំ២០២០ និងការធ្វើចត្តាឡីស័កចំពោះប្រជាពលរដ្ឋទាំងឡាយណា ដែលធ្វើដំណើរក្នុងអំឡុងពេលហាមឃាត់។

ប្រជាកសិករជិត៦០.២ភាគរយ ឆ្លើយថាពួកគេ មិនបានទទួលដំណឹងពីផែនការរបស់រាជរដ្ឋាភិបាលទៅលើការដោះស្រាយផលប៉ះពាល់របស់មេរោគកូវីដ ១៩ ទាក់ទងនឹងសុខភាព សង្គម និងសេដ្ឋកិច្ចមកលើប្រជាសហគមន៍នៅឡើយទេ។

ស្របពេលដែរជាង៨២.៥ភាគរយ ថាមិនបានទទួលព័ត៌មានពីកម្មវិធីឥណទានដែលមានការប្រាក់ទាបដើម្បីផ្តល់ការគាំទ្រដល់សិប្បកម្ម សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកែច្នៃផលិតផលកសិកម្ម វិស័យកសិឧស្សាហកម្ម និងវិស័យកសិកម្មតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដែលមានទឹកប្រាក់ចំនួន៥០លានដុល្លារក្នុងអំឡុងនៃវិបត្តិមេរោគកូវីដ ១៩។




*ការផ្សព្វផ្សាយព័ត៌មានពីផែនការគាំទ្រ*

ប្រជាកសិករត្រឹមតែ១៣ភាគរយប៉ុណ្ណោះ ដែលបានដឹងពីព័ត៌មានទាក់ទងទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។ ប្រជាកសិករមួយចំនួន លើកឡើងនូវក្តីបារម្ភជុំវិញការអនុម័តច្បាប់មួយនេះ។

ប្រភពព័ត៌មានសំខាន់ៗដែលប្រជាកសិករទទួលបានមានដូចជាបណ្តាញព័ត៌មានសង្គម (ភាគច្រើនតាមរយៈហ្វេសប៊ុក និងយូធូប) ការផ្សព្វផ្សាយរបស់អាជ្ញាធរមូលដ្ឋាន (ប្រព័ន្ធឃោសនស័ព្ទ តាមរថយន្ត ម៉ូតូ ចុះតាមផ្ទះជាដើម) ព័ត៌មានប្រពៃណីដូចជា ទូរទស្សន៍ វិទ្យុ កាសែត និងការផ្សព្វផ្សាយជាផ្លូវការរបស់រដ្ឋាភិបាល។

## ៥.២ បទពិសោធ និងទស្សនៈរបស់ប្រជាកសិករទាក់ទងទៅនឹងវិធាន និងយន្តការរបស់រាជរដ្ឋាភិបាល

ប្រជាកសិករមួយចំនួន សម្តែងការពេញចិត្តចំពោះសេចក្តីជូនដំណឹង វិធាន និងការអនុវត្តបទបញ្ជាមួយចំនួនរបស់រាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ និងពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ពួកគេចាត់ទុកថា បទបញ្ជាទាំងនោះដែលរួមទាំងបទបញ្ជាស្តីពីការហាមឃាត់ការធ្វើដំណើរឆ្លងស្រុកខេត្តទូទាំងប្រទេស ការដាក់ដាច់ដោយឡែក(ចត្តាឡីស័ក) ចំពោះប្រជាពលរដ្ឋដែលត្រឡប់ពីធ្វើការក្រៅប្រទេស ការរឹតបណ្តឹងការជួបជុំជាសាធារណៈ ឬការរៀបចំពិធីមង្គលការ និងពិធីសាសនាជាដើម ត្រូវបានអនុវត្តឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព ស្ថេរភាព និងបង្ការការពារការឆ្លងមេរោគកូវីដ ១៩ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងនៅក្នុងសហគមន៍ទាំងមូល។

ទោះជាយ៉ាងនេះក្តី ប្រជាកសិករមួយចំនួនទៀត ក៏បានបង្ហាញពីអារម្មណ៍មិនពេញចិត្ត និងព្រួយបារម្ភចំពោះវិធានទាំងនោះ។

ការអនុវត្តអនុក្រឹត្យស្តីពីការលើកការឈប់សម្រាកការងាររបស់មន្រ្តីរាជការ និយោជិតកម្មករនៅថ្ងៃទី ១៣ ទី១៤ ទី១៥និងទី១៦ ខែមេសា ឆ្នាំ២០២០ ការហាមឃាត់ធ្វើដំណើរក្នុងប្រទេស និងឆ្លងកាត់ចេញចូលរាជធានីភ្នំពេញ និងឆ្លងកាត់ពីស្រុកមួយទៅស្រុកមួយ និងខេត្តមួយទៅខេត្តត្រូវបានដាក់ឲ្យអនុវត្ត និងចាត់វិធានការភ្លាមៗ បង្កឲ្យមានការព្រួយបារម្ភ និងភ័យខ្លាចជាពិសេសនៅពេលមានការចល័តយោធា និងការដាក់បរ៉ាស់បិទលើផ្លូវជាតិ និងផ្លូវលំមួយចំនួន។ សម្រាប់ពួកគេការអនុវត្តវិធាននេះ ហាក់បង្ហាញនូវអស្ថេរភាព និងស្ថានភាពដែលប្រទេសជាតិកំពុងតែខិតចូលទៅរកគ្រាអាសន្ន។ ស្ថានភាពនេះមានភាពធូរស្បើយមកវិញបន្ទាប់ពីមានការប្រកាសឲ្យធ្វើការឆ្លងកាត់ស្រុកខេត្តនីមួយៗ ជាធម្មតាវិញ។

ការហាមឃាត់ការធ្វើដំណើរតាមច្រកព្រំដែនលើកលែងតែទំនិញដោះដូរជាយុទ្ធសាស្រ្ត ធ្វើឲ្យប្រជាកសិករដែលប្រកបរបរដោះដូរទំនិញជាមួយឈ្មួញពីប្រទេសជិតខាង តាមរយៈច្រករបៀង ឬព្រំដែនភាគច្រើនផ្អាករបរចិញ្ចឹមជីវិតរបស់ពួកគ។ ពួកគេថា ពួកគេអាចប្រឈមទៅនឹងការដាច់បាយ និងបាត់បង់ផ្ទះសម្បែងដោយសារមិនមានលទ្ធភាពសងបំណុលប្រសិនបើស្ថានភាពច្រកនៅតែបន្តបិទ។ ប្រជាកសិករមួយចំនួនទៀតដែលរស់នៅអាស្រ័យផលពីអនុផលព្រៃឈើ ក៏បានត្អូញត្អែរផងដែរថា ពួកគេមិនអាចរកចំណូលបានដូចមុនដោយសារមិនមានឈ្មួញកណ្តាលមកទិញផលិតផលរបស់ពួកគេទៀតឡើយ។

បើទោះជាការប្រកាសឲ្យទំនិញលក់នៅក្នុងតម្លៃធម្មតាក៏ដោយ ក៏ប៉ុន្តែតម្លៃទំនិញនៅលើទីផ្សារមួយចំនួននៅក្នុងតំបន់ដែលប្រជាកសិកររស់នៅមានការឡើងថ្លៃ។

ប្រជាកសិករមួយចំនួនយល់ឃើញថា ការរឹតត្បិតការជួបជុំ និងការប្រមូលផ្តុំជាសាធារណៈបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពក្នុងការដើរហើរ និងការជួបជុំគ្នារបស់ពួកគេ។

បទបញ្ហារបស់រាជរដ្ឋាភិបាលក្នុងការដាក់ដាច់ដោយឡែក (ចត្តាឡីស័ក) ចំពោះប្រជាពលរដ្ឋដែលត្រឡប់ពីធ្វើការនៅប្រទេសក្រៅ (ដូចជាប្រទេសម៉ាឡេស៊ី ប្រទេសថៃនិងប្រទេសដទៃទៀត) និងប្រជាពលរដ្ឋមួយចំនួនទៀតដែលត្រឡប់ពីខេត្តមួយចំនួនក្នុងអំឡុងពេលហាមប្រាម បានបង្កើតឲ្យមានការរើសអើង និងភាពមិនទុកចិត្តគ្នាពីសំណាក់ប្រជាកសិករមួយចំនួនដែលកំពុងរស់នៅតាមមូលដ្ឋាន ទៅលើប្រជាពលរដ្ឋដែលបានវិលត្រឡប់ពីបរទេស ឬទៅជួបជុំក្រុមគ្រួសាររបស់ពួកគេ។

ប្រជាកសិករមួយចំនួនបង្ហាញពីចង្ងល់ និងក្តីបារម្ភមួយចំនួនទៅលើការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងគ្រាអាសន្នដូចជាថាតើមានភាពចាំបាច់អ្វីខ្លះ ដែលជម្រុញឲ្យមានការបង្កើតច្បាប់នេះឡើង និងអនុម័តយ៉ាងឆាប់រហ័សបែបនេះ? ស្របពេលដែលប្រជាកសិករមួយចំនួនទៀត លើកឡើងថាការសិក្សាជាមុនអំពីលទ្ធភាពនៃផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើងពីច្បាប់នេះនាពេលអនាគត ហាក់មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ផងដែរនោះ ប្រជាកសិករមួយចំនួនទៀតប្រាប់ថា ពួកគេមិនធ្លាប់ទទួលបានការផ្សព្វផ្សាយពីខ្លឹមសារនៃច្បាប់នេះឡើយទេ។

គួសបញ្ជាក់ សេចក្តីស្នើច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដែលត្រូវបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ និងត្រូវបានពិនិត្យនូវធម្មនុញ្ញរួចរាល់កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ព្រមទាំងត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រម ចុះនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។[28] អង្គការសង្គមស៊ីវិលទាំងក្នុង និងក្រៅស្រុកមួយចំនួនក៏មានការព្រួយបារម្ភណ៍ទៅលើផលប៉ះពាល់របស់ច្បាប់នេះផងដែរ។ តាមរយៈអត្ថបទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់នេះ ដែលត្រូវបានធ្វើឡើងដោយស្ថាប័នឃ្លាំមើលសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ បន្ទាប់ពីពង្រាងច្បាប់នេះ បានបែកធ្លាយជាសាធារណៈកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ បានសសេរថា ពង្រាងច្បាប់នេះនឹងផ្តល់អំណាចយ៉ាងទូលាយ និងគ្មានដែនកំណត់ដល់រាជរដ្ឋាភិបាលកម្ពុជាដោយមិនមានយន្តការត្រួតពិនិត្យណាមួយនោះទេ។[29] បន្ថែមពីលើការផ្តល់អំណាចនេះ អត្ថបទវិភាគច្បាប់នេះក៏បានលើកឡើងថា មិនមានការកំណត់ពេលវេលាបញ្ចប់ច្បាស់លាស់ ហើយការប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្នទៀតសោត អាចនឹងត្រូវបានធ្វើឡើងក្នុងរយៈពេលយូរអង្វែង។ សិទ្ធិសេរីភាពជាច្រើន អាចនឹងត្រូវបានហាមឃាត់ ឬរឹតត្បិត ដោយមិនកំណត់ថេរ

---

[28] "ព្រះរាជក្រម នស/រកម/០៤២០/០១៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្នដែលសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ ២០២០ ត្រូវបានត្រួតពិនិត្យចប់សព្វគ្រប់ទៅលើទម្រង់ និងគតិច្បាប់នេះទាំងស្រុងដោយព្រទ្ធិសភាកាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ និងបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញក្នុងសេចក្តីសម្រេចលេខ ២០២/០០២/២០២០ កមធចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២០។" ដកស្រង់ចេញពីគេហទំព័ររបស់ទីស្តីការគណៈរដ្ឋមន្ត្រី។
ចុះផ្សាយថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០ https://pressocm.gov.kh/archives/65972

[29] "បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" អង្គការច្បាប់អន្តរជាតិអេហ្វអាយឌីអេជ និងក្រុមអ្នកការពារសិទ្ធិមនុស្សស៊ីវិល។
https://www.fidh.org/IMG/pdf/20200407_cambodia_analysis_soe_bp_kh.pdf

វេលា។ សិទ្ធិសេរីភាពដែលប៉ះពាល់រួមមានសិទ្ធិក្នុងការធ្វើដំណើរ ការជួបជុំ ឬប្រមូលផ្តុំ ការធ្វើសកម្មភាពការងារ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការបញ្ចេញមតិ។[30] ឯកសារដដែរនេះ បង្ហាញថាទណ្ឌកម្មព្រហ្មទណ្ឌដែលមិនអាចកំណត់ទុកជាមុន និងមានលក្ខណៈមិនសមាមាត្រនឹងអំពើល្មើស អាចនឹងត្រូវបានប្រើប្រាស់ទៅលើប្រជាពលរដ្ឋ តាមរយៈការចោទប្រកាន់ពីបទល្មើសជាច្រើន ដែលមាននិយមន័យមិនច្បាស់លាស់។[31]

ប្រជាកសិករមួយចំនួនបង្ហាញការយល់ឃើញរបស់ពួកគេថា ច្បាប់ បំរាម និងសេចក្តីប្រកាសមួយចំនួនអាចផ្តល់ឱកាសដល់មនុស្សភាគតិច ឬក្រុមអ្នកមានអំណាចមួយចំនួនតូចធ្វើសកម្មភាពតាមទំនើងចិត្តរបស់ពួកគេ។ រីឯប្រជាពលរដ្ឋមូលដ្ឋាន ឬមនុស្សស្រទាប់ក្រោម មានការភ័យខ្លាចបាក់ស្បាតដោយសារមិនមានព័ត៌មានគ្រប់ជ្រុងជ្រោយ។ ហើយអ្វីដែលខ្លាចជាងគេបំផុតនោះ គឺបញ្ហាប្រឈមទៅនឹងទោសទណ្ឌដោយសារការនិយាយ ឬសរសេរព័ត៌មានពិតដែលកើតឡើងនៅក្នុងសហគមន៍របស់ពួកគេ ដែលរួមទាំងព័ត៌មាននានាពាក់ព័ន្ធនិងមេរោគកូវីដ ១៩។

ចំណុចដែលគួរឲ្យកត់សម្គាល់ផងដែរនោះ ប្រជាកសិករមួយចំនួនដែលបានចូលរួមក្នុងសកម្មភាពការពារព្រៃឈើ និងអភិរក្សជលផល លើកឡើងថា បើទោះបីជាមានបម្រាមរឹតត្បិតការធ្វើការជួបជុំ ឬធ្វើដំណើរ ក៏ប៉ុន្តែ វិធានទាំងនោះហាក់មិនមានប្រសិទ្ធភាពបញ្ឈប់ឈ្មួញ ឬជនល្មើសដែលចូលទៅទន្រ្ទានកាប់ព្រៃ និងធ្វើនេសាទខុសច្បាប់នៅឡើយនោះទេ។

ប្រជាកសិករមួយចំនួន លើកឡើងពីឧបសគ្គដែលធ្វើឲ្យពួកគេមិនទទួលបានការគាំទ្រពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជួយគ្រួសារក្រីក្រពីរាជរដ្ឋាភិបាល នៅកិច្ចប្រជុំពិគ្រោះយោបល់ពីរបកគំហើញនៃរបាយការណ៍ស្រាវជ្រាវនេះ នាដើមខែសីហា។ ឧបសគ្គមួយក្នុងចំណោមឧបសគ្គដទៃគឺ ពួកគេមិនមានប័ណ្ណសមធម៌ ឬ អស់សុពលភាព។ សម្រាប់កសិករដែលមិនមានប័ណ្ណសមធម៌ប្រាប់ថា ពួកគេមិនដែលបានប័ណ្ណនេះទេបើទោះបីជាជីវភាពពួកគេមានភាពលំបាកយ៉ាងណាក្តី។

---

30 "បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" អង្គការច្បាប់អន្តរជាតិអេហ្វអាយឌីអេជ និងក្រុមអ្នកការពារសិទ្ធិមនុស្សស៊ីវិល។ https://www.fidh.org/IMG/pdf/20200407_cambodia_analysis_soe_bp_kh.pdf

31 "បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" អង្គការច្បាប់អន្តរជាតិអេហ្វអាយឌីអេជ និងក្រុមអ្នកការពារសិទ្ធិមនុស្សស៊ីវិល។ https://www.fidh.org/IMG/pdf/20200407_cambodia_analysis_soe_bp_kh.pdf

# ៦. បទពិសោធពីផលប៉ះពាល់នានានៃវិបត្តិការរាតត្បាតពីជំងឺកូវីដ១៩

## ៦.១. ផលប៉ះពាល់មកលើសុខភាព និងបទពិសោធនៃការប្រើប្រាស់ សេវាសុខាភិបាលរបស់ប្រជាកសិករ

ប្រជាកសិករ ចំនួន១១.៥ភាគរយ ថាពួកគេបានទទួលសម្ភារៈបង្ការ និងការពារខ្លួនមួយចំនួនដូចជាសាប៊ូ និងអាល់កុល។ ដោយឡែកប្រជាកសិករ៨៧.៥ភាគរយផ្សេងទៀត មិនបានទទួលសម្ភារៈការពារខ្លួនដែលឧបត្ថម្ភ ពីរាជរដ្ឋាភិបាល ឬ អាជ្ញាធរមូលដ្ឋាននោះទេ។




ពួកគេថា បានចំណាយទៅលើសម្ភារៈទាំងនោះដើម្បីការពារអាយុជីវិតរបស់ពួកគេ និងសមាជិកនៅក្នុងគ្រួសារ។ ការណ៍នេះ បានបន្ថែមបន្ទុកមួយទៀតសម្រាប់ពួកគេដែលកំពុងប្រឈមវិបត្តិជាច្រើន។

ប្រជាកសិករ ៩៦នាក់ (៩២.៣ភាគរយ) ឆ្លើយថាមិនទាន់មានរោគសញ្ញានៃការឆ្លង ឬរីករាលដាលណាមួយនៃមេរោគកូវីដ ១៩ កើតឡើងនៅក្នុងចំណោមមនុស្សដែលរស់នៅជិតស្និតជាមួយពួកគេ ឬ ប្រជាពលរដ្ឋដទៃទៀតដែលកំពុងរស់នៅក្នុងសហគមន៍នៅឡើយទេ។

ការធ្វើតេស្តរកមេរោគកូវីដ ១៩ និងការសម្រាកថែទាំព្យាបាលជំងឺនេះ គឺមិនត្រូវបានតម្រូវឲ្យបង់ថ្លៃនោះទេ។ ក្រសួងសុខាភិបាលផ្តល់សេវាថែទាំជំងឺនេះដោយឥតគិតថ្លៃ បើទោះបីជាប្រទេសកម្ពុជា កំពុងអនុវត្តនូវកម្មវិធីបង់ថ្លៃលើសេវាថែទាំ និងព្យាបាលសុខភាពក្តី។ ការអនុវត្តនូវការមិនយកថ្លៃលើសេវាព្យាបាលជំងឺនេះ ទទួលបានការកោតសសើរពីប្រជាពលរដ្ឋខ្មែរ។

ដោយឡែក ឧបសគ្គចម្បងដែលប្រជាកសិករជួបប្រទះទៅលើបញ្ហាសុខភាពរបស់ពួកគេ ឬសមាជិកនៅក្នុងគ្រួសារ គឺជុំវិញលទ្ធភាពចំណាយទៅលើការប្រើប្រាស់សេវាថែទាំ និងព្យាបាលសុខភាពទាំងនៅមន្ទីរពេទ្យឯកជន និងមន្ទីរពេទ្យសាធារណៈ។ អ្វីដែលគួរឲ្យកត់សម្គាល់ការចំណាយទៅលើការថែទាំសុខភាពមិន

មែនតែជាបន្ទុករបស់ប្រជាកសិករនោះទេ ក៏ប៉ុន្តែដោយសារការអនុវត្តនូវប្រព័ន្ធហិរញ្ញប្បទានសព្វថ្ងៃ ការចំណាយនានាទៅលើសេវាសុខាភិបាល គឺត្រូវធ្លាក់មកជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋដោយផ្ទាល់។ បញ្ហានៃការចំណាយច្រើនរបស់ប្រជាពលរដ្ឋទៅលើការព្យាបាលជំងឺ ក៏បានរុញច្រានឲ្យប្រជាពលរដ្ឋជាច្រើននាក់ផ្សេងទៀត ធ្លាក់ក្នុងវិបត្តិហិរញ្ញវត្ថុគ្រួសារ និងធ្លាក់ទៅក្នុងបំណុល។[32] បញ្ហានេះបន្តកើតឡើងជាច្រើនឆ្នាំមកហើយ ហើយបើទោះបីជាការចំណាយរបស់ប្រជាពលរដ្ឋហាក់មានការថយចុះ ប្រៀបធៀបទៅនឹងឆ្នាំកន្លង ក៏ប៉ុន្តែក៏ចំណាយច្រើនលើសេវាចាំបាច់មួយនេះស្ថិតនៅជាបន្ទុករបស់ប្រជាពលរដ្ឋ និងប្រជាកសិករនៅឡើយ។ ប្រជាកសិករអាចនឹងប្រឈមទៅនឹងផលវិបាកនានាបន្ថែមទៀត ជាពិសេសផលលំបាកនៃការចំណាយ ប្រសិនបើពួកគេ ឬសមាជិកគ្រួសារណាម្នាក់ធ្លាក់ខ្លួនឈឺ ស្របពេលដែលពួកគេកំពុងទទួលរងផលប៉ះពាល់មួយចំនួនដែលបណ្តាលមកពីវិបត្តិនៃការរាតត្បាតពីជំងឺកូវីដ ១៩។

## ៦.២. ផលប៉ះពាល់មកលើជីវភាពប្រចាំថ្ងៃរបស់ប្រជាកសិករ



*ក្រុមគ្រួសារកសិករនៅក្នុងខេត្តពោធិ៍សាត់*

[32] Por Ir, Bart Jacobs, Augustine D Asante, Marco Liverani, Stephen Jan, Srean Chhim, and Virginia Wiseman, “Exploring the determinants of distress health financing in Cambodia”. OXFORD. *Health Policy and Planning, /volume 34, Issue Supplement_1, October 2019. Accepted on 17 January, 2019.* https://academic.oup.com/heapol/article/34/Supplement_1/i26/5603549

វិស័យកសិកម្មជាប្រភពចំណូលដ៏ចម្បងរបស់ប្រជាកសិករភាគច្រើន។ កសិករខ្នាតតូច និងមធ្យម នៅបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតស្បៀងសម្រាប់ចិញ្ចឹម ប្រជាពលរដ្ឋផ្សេងទៀតទូទាំងប្រទេស។

ប្រជាកសិករជាងពាក់កណ្តាលថាខ្លួន ដែលជាឪពុក ឬ ជាប្តីគឺជាអ្នករកចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រជាកសិករជាង៣០ភាគរយផ្សេងទៀត ក៏បានផ្តល់ចម្លើយផ្សេងគ្នាថាប្រពន្ធរបស់ខ្លួនគឺជាអ្នករកចំណូលចម្បងដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្រៅពីចម្លើយខាងលើ ប្រជាកសិករមួយចំនួនប្រាប់ថាកូនស្រីឬប្រុសរបស់ពួកគេជាអ្នករកចំណូលយ៉ាងសំខាន់សម្រាប់គ្រួសារ។

ភាគច្រើននៃប្រជាកសិករនៅតាមទីជនបទ និងដាច់ស្រយ៉ាលធ្វើស្រែទៅតាមរដូវកាល។ ក្រៅពីប្រកបរបរធ្វើស្រែ ប្រភពចំណូលបន្ទាប់បន្សំគឺនេសាទ និងលក់កម្លាំង។ ការនេសាទភាគច្រើនសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេ ស្ទឹង អូរ ឬប្រឡាយសាធារណៈជាដើម។ អនុផលព្រៃឈើក៏ជាប្រភពដ៏សំខាន់សម្រាប់ផ្គត់ផ្គង់តម្រូវការ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាកសិករមួយចំនួនដែលរស់នៅក្នុងតំបន់ព្រៃឈើ ភាគច្រើនគឺជនជាតិដើមភាគតិច។

បន្ទាប់ពីការធ្វើស្រែចំការ ប្រជាកសិករចំនួន៣៣.៧ភាគរយ ប្រាប់ថាធ្វើការស៊ីឈ្នួលប្រើកម្លាំង។ ការងារទាំងនោះ មានដូចជា ការស៊ីឈ្នួលធ្វើការផ្ទះ កម្មករសំណង់ ធ្វើជាជាងម៉ាស៊ីន កម្មករនៅក្នុងចំការ កម្មករចិញ្ចឹមសត្វឲ្យកសិដ្ឋានធំៗ និងស៊ីឈ្នួលយាមផ្ទះឲ្យគេជាដើម។ល។

ប្រជាកសិករមួយចំនួនទៀតពឹងផ្អែកទៅលើប្រាក់បញ្ញើរពីសមាជិកនៅក្នុងគ្រួសារ ដែលធ្វើការក្នុងរោងចក្រកាត់ដេរ ជាបុគ្គលិកក្នុងគ្រឹះស្ថានកំសាន្ត និងចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស (ថៃ ប្រទេសម៉ាឡេស៊ី ឬប្រទេសកូរ៉េខាងត្បូង) ជាដើម។ល។ ប្រជាកសិករតិចតួចណាស់ដែលមានមុខរបរបន្ទាប់បន្សំជាអ្នកលក់ដូរ ឬក៏ជាមន្ត្រីរាជការ។

ប្រជាកសិករ៤១.៣ភាគរយ កំពុងធ្វើការ ឬប្រកបរបរកចិញ្ចឹមជីវិតជាធម្មតានាអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ ១៩។ មូលហេតុដែលពួកគេអាចប្រកបររបរដូចធម្មតា ដោយសារប្រភេទនៃមុខរបរទាំងនោះ មិនតម្រូវឲ្យពួកគេចាកចេញពីភូមិ ឬសហគមន៍របស់ពួកគេឡើយ។ ក៏ប៉ុន្តែប្រជាកសិករចំនួន៤១.៣ភាគរយ មិនមានចំណូលដូចពីមុននោះទេដោយសារប្រភេទមុខរបរដែលពួកគេធ្វើ (ការស៊ីឈ្នួលគេ) ត្រូវបានផ្អាកដំណើរការមួយរយៈហើយ។

## ៦.៣. ស្ថានភាព និងផលប៉ះពាល់មកលើទីផ្សារផលិតផលកសិកម្មរបស់ប្រជាកសិករ

ប្រជាកសិករជាងពាក់កណ្តាល (៥០.៥ភាគរយ) បានកំពុងបន្តផលិតកសិផល ឬដាំដំណាំក្នុងអំឡុងពេលនេះ។ ប្រជាកសិករ៤៩.៥ភាគរយ មិនបានផលិត ឬដាំដំណាំទេដោយសារតែបញ្ហាកង្វះទឹកដែលបណ្តាលពីភាពរាំងស្ងួត។

ក្នុងចំណោមប្រជាកសិករដែលកំពុងផលិត ឬដាំដំណាំនេះទៀតសោត ចំនួន៥៤.២ភាគរយ ថាពួកគេមិនមានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម។ នៅពេលដែរប្រជាកសិករ៤៥.៨ភាគរយ មានទីផ្សារសម្រាប់លក់ដោះដូរផលិតផលក្នុងស្រុក។

សម្រាប់ប្រជាកសិករមួយចំនួន បើទោះជាមានទីផ្សារសម្រាប់លក់ផលិតផលកសិកម្មក៏ដោយ ពួកគេនៅតែមិនអាចកំណត់តម្លៃផលិតផលកសិកម្មរបស់ខ្លួនបាននៅឡើយទេ។ ប្រជាកសិករ៧៥ភាគរយ ឆ្លើយថា ឈ្មួញកណ្ដាលនៅតែដើរតួនាទីសំខាន់ក្នុងការកំណត់តម្លៃទៅលើផលិតផលកសិកម្ម នៅពេលចរចាទិញលក់ម្ដងៗ។ ដោយសារមិនមានជម្រើស និងប្រឈមទៅនឹងភាពខូចខាតនៃដំណាំ ឬកសិផលដែលបានប្រមូលផលរួច ប្រជាកសិករតែងតែស្របជាមួយតម្លៃដែលឈ្មួញកណ្ដាលដាក់ បើទោះជាតម្លៃនោះទាបយ៉ាងណាក្ដី។

ដោយឡែកប្រជាកសិករត្រឹមតែ១៦.៣ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពកំណត់តម្លៃកសិផលរបស់ខ្លួន។ ស្រដៀងគ្នានេះ ប្រជាកសិករ២.៩ភាគរយកំពុងអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម។ គម្រូទីផ្សារតាមបែបកិច្ចសន្យាលើផលិតកម្មកសិកម្មហាក់មានការប្រើប្រាស់ និងជម្រុញជាខ្លាំងនៅក្នុងអំឡុងនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវិដ ១៩។ ការកំណត់តម្លៃនេះ បង្ហាញពីវិសមភាពនៃអំណាចរវាងឈ្មួញកណ្ដាលជាមួយនឹងប្រជាកសិករ ឬអ្នកផលិត និងដាំដុះ ខ្នាតតូច និងមធ្យមនៅបន្តមាននៅក្នុងវិស័យនេះ។



*កសិករដាំដំណាំពោតនៅក្នុងខេត្តបាត់ដំបង*

បញ្ហានេះ បានបន្តកើតឡើងជាច្រើនលើកច្រើនសារដែលអាចនឹង បណ្តាលឲ្យប្រជាកសិករមួយចំនួនសម្រេចចិត្តជ្រើសរើសឈប់ប្រកបរបរកសិកម្ម ចំណាកស្រុកទៅលក់កម្លាំងពលកម្ម ឬ ធ្លាក់ទៅក្នុងបំណុល និងភាពក្រីក្រ។[33]

ចំពោះទម្រង់ទីផ្សារតាមបែបកិច្ចសន្យាលើផលិតកម្មកសិកម្មហាក់ស្ថិតនៅជាមន្ទិល និងជាសំណួរនៅឡើយជាពិសេសជុំវិញអំណាច និងការសម្រេចចិត្តទៅលើការផលិតការកំណត់តើតម្លៃ និងគុណភាព ឬការដាក់ស្តង់ដាជាដើម រវាងក្រុមហ៊ុន ឬទីផ្សារជាមួយនឹងប្រជាកសិករ។ តំណាងកសិករមួយចំនួន បានលើកឡើងនៅក្តីបារម្ភរបស់ពួកគេទៅលើគម្រូនេះ ជាពិសេសជាមួយនឹងភាពស្រពិចស្រពិលនៃអំណាច និងភាពជាម្ចាស់ទៅលើការផលិត និងការជ្រើសរើសការផលិតរបស់ពួកគេ។




*កសិផលរបស់ប្រជាកសិករដែលដឹកតាមទូកកំឡុងពេលការរាតត្បាតនៃជំងឺកូវីដ ១៩ ក្នុងខេត្តកំពង់ឆ្នាំង*

[33] Sophea Chrek, Current Paddy Rice Price Crisis: Wake-Up Call on a More Systemic Problem. Focus on the Global South. Oct 26, 2016. https://focusweb.org/current-paddy-rice-price-crisis-wake-up-call-on-a-more-systemic-problem/

*តារាង៖ បង្ហាញពីផលប៉ះពាល់នៃវិបត្តិកូវីដ ១៩ មកលើប្រភពចំណូលចម្បងៗរបស់ប្រជាកសិករ និងគ្រួសាររបស់ពួកគេ*

- ទីផ្សារសម្រាប់កសិផលដំណាំឧស្សាហកម្ម (ដំឡូងមី និងគ្រាប់ស្វាយចន្ទី) មានការធ្លាក់ចុះ ដោយសារមិនសូវមានឈ្មួញចុះទិញ ហើយបើទោះជាឈ្មួញចុះទិញគឺក្នុងតម្លៃទាបខ្លាំងបើប្រៀបធៀបទៅឆ្នាំមុនៗ។ នៅតំបន់ខ្លះ មិនមានឈ្មួញចុះទិញកសិផលប្រភេទនេះតែម្តង។
- កសិផល ឬដំណាំកសិកម្មមួយចំនួនទៀតដូចជាបន្លែ ត្រី មាន់ទា មានទីផ្សារ ឬនៅបន្តមានតម្រូវការច្រើនពីអ្នកទទួលទាន ក៏ប៉ុន្តែតម្លៃនៃកសិផល និងដំណាំទាំងនេះ នៅទាបនៅឡើយ។ ប្រជាកសិករ/អ្នកស្រែភាគតិច ដែលទទួលបានតម្លៃសមរម្យពីការលក់កសិផលរបស់ខ្លួននាអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩។
- បាត់បង់មុខរបរបន្ទាប់បន្សំដោយសារការងារការផ្អាកដំណើរការ និងមិនមានការជួលការងារទាំងនោះ។
- ទទួលរងការកេងប្រវ័ញ្ចពីថៅកែ ឬ ម្ចាស់ម៉ៅការសំណង់ដូចជាការមិនបើកប្រាក់ថ្លៃកម្លាំងពលកម្ម ឬមិនផ្តល់ថ្លៃឈ្នួលប្រចាំថ្ងៃគ្រប់ នៅពេលពួកគេមួយចំនួនចេញទៅធ្វើការកម្មករសំណង់នៅទីក្រុងភ្នំពេញ ដោយគ្មានការងារធ្វើនៅក្នុងភូមិ។
- កូនចៅបាត់បង់ការងារ ឬចំណូលដែលធ្លាប់មានជាប្រចាំ។ ប្រជាកសិករដែលមានកូនធ្វើការនៅក្នុងវិស័យកាត់ដេរ សេវាកំសាន្ត ឬធ្លាប់ចំណាកស្រុកទៅប្រទេសដទៃដើម្បីលក់កម្លាំងពលកម្ម ទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសាររោងចក្រមួយចំនួនបានផ្អាកដំណើរការ ឬបិទទ្វារ ការផ្អាកដំណើរការនៃគ្រឹះស្ថានកំសាន្ត និងការបញ្ជូនត្រឡប់នៃប្រជាពលរដ្ឋដែលធ្លាប់ទៅធ្វើការនៅក្រៅប្រទេសមកស្រុកកំណើតវិញដោយគ្មានការងារធ្វើ ឬ ជម្រើសអ្វីជំនួស។
- ក្រៅពីការបាត់បង់ចំណូល ប្រជាកសិករត្រូវទទួលបន្ទុកបន្ថែមទៅលើការរស់នៅនៃសមាជិកគ្រួសារដែលវិលត្រឡប់មកស្រុកកំណើតវិញក្នុងគ្រាមានវិបត្តិ។
- កូនៗរបស់ពួកគេមួយចំនួនមិនបានទៅរៀន។ ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកតម្រូវឲ្យមានការចំណាយបន្ថែម បានបន្ថែមបន្ទុកមួយទៀតសម្រាប់ប្រជាកសិករ។

## ៦.៤. ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះស្បៀងអាហារ និងទឹកសម្រាប់ទទួលទាន ដាំដុះ និងប្រើប្រាស់របស់ប្រជាកសិករ

### ៦.៤.១. ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះស្បៀងអាហាររបស់កសិករ

ប្រជាកសិករចំនួន៥៩.៨ភាគរយនៃអ្នកចូលរួម១០៤នាក់បានឆ្លើយថា មិនមានអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ក្នុងក្រុមគ្រួសារនាពេលបច្ចុប្បន្ន ឬអំឡុងពេលនៃកិច្ចសម្ភាសន៍នោះទេ។ ប្រជាកសិករ៣៤ភាគរយ ឆ្លើយថាពួកគេគ្មានអាហារបម្រុងទុកទេ ប្រសិនបើស្ថានភាពនៃការវិបត្តិនៅបន្តមាន។







*កង្វះស្បៀងអាហារ និងរយៈពេល*

ប្រជាកសិករ១៨ភាគរយ ប្រាប់ថាពួកគេមានអាហារបម្រុងទុកក្នុងផ្ទះដែលអាចផ្គត់ផ្គង់គ្រួសាររបស់ពួកគេតិចជាងមួយខែ។ រីឯ២៣ភាគរយផ្សេងទៀតមានលទ្ធភាពបម្រុងអាហារទុកលើសពី៥ខែ។

សម្រាប់ប្រជាកសិករមួយចំនួនដែលមានអាហារសម្រាប់បម្រុងទុក គឺដោយសារប្រភពស្បៀងទាំងនោះបានមកពីការដាំដំណាំជាលក្ខណៈគ្រួសារ មានស្រះទឹក ចិញ្ចឹមសត្វ និងមានស្រូវសល់ពីឆ្នាំមុនខ្លះ។ ប្រជាកសិករមួយចំនួនទៀត មានលទ្ធភាពទិញស្បៀងអាហារសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ពួកគេក្នុងអំឡុងវិបត្តិកូវីដ ១៩នេះ។

ផងដែរនោះ ប្រជានេសាទដែលចូលរួមក្នុងកិច្ចសម្ភាសន៍នេះ មានការខ្វះខាតជាខ្លាំងដោយសារពួកគេមិនអាចរកចំណូលបានពីការនេសាទដូចមុន។ ការធ្លាក់ចុះនូវធនធានត្រី បន្តកើតឡើងជារៀងរាល់ឆ្នាំ។ ការណ៍នេះ ធ្វើអោយប្រជានេសាទប្រឈមទៅនឹងកង្វះស្បៀងអាហារ។ បញ្ហារាំងស្ងួត ឬទឹករាក់ជាងឆ្នាំមុនៗ ក៏ជាបញ្ហាប្រឈមខ្លាំងសម្រាប់ប្រជានេសាទមួយចំនួនដែលមានដីធ្លីបន្តិចបន្តួចសម្រាប់ដាំដុះ ឬធ្វើស្រែចំការដោយសារពួកគេមិនអាចពឹងពាក់ទៅលើការដាំដុះបាន។

## ៦.៤.២. ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះទឹកសម្រាប់ទទួលទាន ដាំដុះ និងប្រើប្រាស់ក្នុងគ្រួសារ

ប្រជាកសិករ៥៧នាក់ (៥៥.៩ ភាគរយ)មិនមានទឹកគ្រប់គ្រាន់សម្រាប់ទទួលទាន ដាំដំណាំ និងប្រើប្រាស់ទូទៅនៅក្នុងគ្រួសារ។

ដោយឡែក ប្រជាកសិករ៤៤.១ ភាគរយ មានទឹកសម្រាប់ទទួលទាន និងប្រើប្រាស់គ្រប់គ្រាន់ពេញមួយឆ្នាំ។ សម្រាប់ប្រជាកសិករមួយចំនួន ដែលមានទឹកសម្រាប់ទទួលទាន ស្រោចស្រពដំណាំ និងប្រើប្រាស់ពេញមួយឆ្នាំ គឺដោយសារពួកគេមានអណ្ដូង ឬស្រះទឹកជាលក្ខណៈគ្រួសារ។



*ទឹកប្រើប្រាស់ និងស្រោចស្រព*

ប្រភពទឹកដែលប្រជាកសិករពឹងផ្អែកទៅលើមានដូចជា៖ អណ្ដូង ស្រះគ្រួសារ ស្រះទឹករួមរបស់សហគមន៍ ស្ទឹង អូរ ទន្លេ និងប្រឡាយទឹក ជាដើម។ បើទោះជាប្រជាកសិករមួយចំនួនរស់នៅជិតប្រភពទឹកសាធារណៈទាំងនេះក៏ដោយ បញ្ហារីងស្ងួត ឬទឹករាក់ជាងមុនធ្វើឲ្យប្រជាកសិករមួយចំនួនត្រូវផ្ដល់អទិភាពទៅលើការចាត់ចែងប្រើប្រាស់ទឹក ដោយធ្វើការផ្ដោតសំខាន់ទៅលើការរក្សាទុកទឹកសម្រាប់ទទួលទាន និងប្រើប្រាស់ចាំបាច់ក្នុងគ្រួសារប៉ុណ្ណោះ។

ប្រជាពលរដ្ឋខ្លះទៀត ទិញទឹកពីអ្នកចែកចាយទឹកឯកជនដែលមានតម្លៃគិតជាពាង ធុង ឬជាឡាន។ យ៉ាងហោចណាស់ ប្រជាកសិករចំណាយពីចន្លោះ៤ម៉ឺន ទៅ១៦ម៉ឺនរៀលក្នុងមួយខែទៅលើថ្លៃទឹកពីអ្នកលក់ចែកចាយឯកជន។

ក្រៅពីប្រភពទឹកខាងលើ ប្រជាកសិករមួយចំនួនក៏ប្រើប្រាស់ទឹកដែលលក់ចែកចាយដោយរដ្ឋាករទឹកកម្ពុជា។ មានប្រជាកសិករមួយចំនួនតូចដែលរស់នៅឆ្ងាយពីប្រភពទឹកស្អាត ដូចនេះពួកគេទិញទឹកសុទ្ធសម្រាប់ទទួលទាន។ ស្របពេលដែល ប្រជាកសិករមួយចំនួនទៀត ដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ពុំមានលទ្ធភាពទិញទឹកសម្រាប់ទទួលទាន ហេតុដូចនេះ ពួកគេប្រើប្រាស់ និងទទួលទានទឹកដែលកខ្វក់។

### ៦.៤.៣. ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះស្បៀងអាហារដែលគ្រួសារក្នុងភូមិ ឬសហគមន៍កំពុងជួបប្រទះ

ស្បៀងអាហារជាប្រភពចាំបាច់ក្នុងភូមិ និងសហគមន៍នីមួយៗ ទិន្នន័យបង្ហាញមានលើសពី៣០ភាគរយ ដែលជាភាគរយខ្ពស់ជាងគេនិងគួរឲ្យផ្តោតយកចិត្តទុកដាក់ បានកំណត់ថាមានចំនួនគ្រួសារលើសពី៥១គ្រួសារ ដែលកំពុងប្រឈមនឹងកង្វះស្បៀងអាហារ។ ក៏មានភាគរយដែលតិចតួចមាន១៦ភាគរយទាំងក្នុងភូមិ និងសហគមន៍បានកំណត់មានគ្រួសារ ប្រឈមនឹងកង្វះស្បៀងមានចន្លោះពី១ទៅ១០គ្រួសារ។ ផងដែលនោះទិន្នន័យដែលមានចន្លោះពី១១និង១៣ភាគរយ ទាំងក្នុងភូមិនិងសហគមន៍ ក៏មិនបានដឹងថាសមាជិករបស់ពួកគេប្រឈមនិងកង្វះស្បៀងឬក៏អត់នោះទេ។

ទន្ទឹមនឹងនេះប្រជាកសិករច្រើនជាងពាក់កណ្តាល (៥៧.៧ភាគរយ) ឆ្លើយថាតម្លៃអាហារមានការឡើងថ្លៃបន្តិចបន្តួច បើធៀបទៅនឹងប្រជាកសិករ ១ភាគ៤ (២៦.៨ភាគរយ) និយាយថា អាហារមានការឡើងថ្លៃខ្លាំងក្នុងអំឡុងវិបត្តិនៃមេរោគកូវីដ១៩នេះ។




*ចំនួនគ្រួសារដែលប្រឈមនឹងកង្វះស្បៀងអាហារ*

### ៦.៤.៤. ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះទឹកដែលគ្រួសារក្នុងភូមិ ឬ សហគមន៍កំពុងជួបប្រទះ

ប្រជាកសិករលើស៣០ភាគរយ ឆ្លើយថាលើស៥១គ្រួសារដែលកំពុងរស់នៅក្នុងភូមិ ឬ សហគមន៍របស់ពួកគេកំពុងប្រឈមនឹងកង្វះទឹក។ ដោយឡែក ប្រជាកសិករ៣០ភាគរយផ្សេងទៀតថា គ្រួសាររបស់ពួកគេ មិនបានប្រឈមនឹងកង្វះទឹកនោះទេ។




*ចំនួនគ្រួសារដែលប្រឈមនឹងកង្វះទឹក*

ចំណែកឯ តម្លៃទឹកវិញ ប្រជាកសិករ៤៨នាក់ (ជិត៥០ភាគរយ) ថាតម្លៃទឹកដែលលក់ចែកចាយដោយឯកជនឡើងថ្លៃបន្តិចបន្តួចនៅក្នុងសហគមន៍របស់ពួកគេ។ ប្រជាកសិករ១៤នាក់ (១៤.៣ភាគរយ) ថាតម្លៃទឹកមានការឡើងថ្លៃខ្លាំង។ ប្រជាកសិករ៣២.៧ភាគរយថាតម្លៃទឹកស្ថិតនៅធម្មតា។

ដោយសារទឹកគឺជាប្រភពសំខាន់សម្រាប់ជីវិត ជីវភាព និងតម្រូវការប្រើប្រាស់ក្នុងគ្រួសារ និងសកម្មភាពកសិកម្មសម្រាប់ប្រជាកសិករ ដូចនេះបើទោះជាតម្លៃទឹកត្រូវបានតម្លើងនៅក្នុងតំបន់មួយចំនួនក៏ដោយក្តី ក៏ប្រជាកសិករទូទៅដែលត្រូវការធនធាននេះជាចាំបាច់ បានប្រើប្រាស់គ្រប់វិធីសាស្ត្រដើម្បីធានាថាពួកគេអាចទទួលបានប្រភពជីវិតដ៏មានសារៈសំខាន់មួយនេះ។

## ៧. ការគាំទ្រ ឬឧបត្ថម្ភពីរាជរដ្ឋាភិបាល




*ការគាំទ្រ ឬ ឧបត្ថម្ភពីរាជរដ្ឋាភិបាល*

បើទោះបីជា ប្រជាកសិករភាគរយច្រើនលើសលប់(៩៥.១ភាគរយ) មិនទទួលបានការគាំទ្រ ឬឧត្ថម្ភនានាពីរាជរដ្ឋាភិបាល គិតមកត្រឹមថ្ងៃសម្ភាសក៏ដោយ (ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០) ក៏ប៉ុន្តែប្រជាកសិករចំនួន៤.៩ភាគរយ ប្រាប់ថាពួកគេធ្លាប់បានទទួលការផ្តល់សម្ភារៈការពារខ្លួន និងអាហារមួយចំនួន នៅអំឡុងពេលការរាតត្បាតពីជំងឺកូវីដ ១៩។ សម្ភារៈការពារខ្លួន និងអាហារដែលប្រជាកសិករទទួលបានការឧបត្ថម្ភរួមមានដូចជា៖ ម៉ាស អាល់កុល សាប៊ូលាងដៃ ក្រម៉ា ថ្នាំ និងស្បៀងអាហារមួយចំនួន (អង្ករ២៥គីឡូសម្រាប់មួយគ្រួសារ ទឹកត្រី២ដប ទឹកស៊ីអ៊ីវ២ដប សៀង ប៊ីចេងមួយកញ្ចប់ ត្រីខកំប៉ុងមួយយួរ ប្រេងឆាមួយដប និងអំបិលកន្លះគីឡូក្រាម)។

ប្រជាកសិករដែលទទួលបានការគាំទ្រខាងលើនេះ មិនបានបញ្ជាក់ច្បាស់ថាការគាំទ្រទាំងនោះផ្តល់ពីរាជរដ្ឋាភិបាលតាមរយៈអាជ្ញាធរមូលដ្ឋាន ឬក៏ជាអំណោយពីបុគ្គលឯកជននោះទេ។ អ្វីដែលគួរឲ្យកត់សម្គាល់ អភិបាលស្រុកមួយរូបក្នុងខេត្តបាត់ដំបង បានចុះចែកសម្ភារៈ និងអាហារទាំងនោះដល់ប្រជាពលរដ្ឋដោយផ្ទាល់។

សម្រាប់ការគាំទ្រ ឬ ឧបត្ថម្ភដោយឡែកផ្សេងទៀតជាពិសេសកម្មវិធីឥណទានឧបត្ថម្ភការធ្វើកសិកម្មរបស់ប្រជាកសិករតាមរយៈធានាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដែលមានទឹកប្រាក់សរុប ៥០លានដុល្លារជាមួយការប្រាក់ទាប ប្រជាកសិករបានឆ្លើយថា មិនទទួលបានផលប្រយោជន៍ពីកម្មវិធីនេះនៅឡើយទេ បើគិតត្រឹមថ្ងៃនៃកិច្ចសម្ភាសន៍។

ស្រដៀងគ្នានេះដែរ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុពេលជំងឺកូវីដ ១៩ ដែលបានដាក់ចុះឲ្យអនុវត្តនាពេលថ្មីៗនេះ (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០) ក៏ហាក់មិនទាន់មានវិសាលភាពគ្រប់ដណ្តប់ទៅលើប្រជាកសិករដែលចូលរួមក្នុងកិច្ចសម្ភាសន៍នៅឡើយទេ។ ជាក់ស្តែង មានការលើកឡើងនូវឧបសគ្គមួយចំនួនរបស់ប្រជាកសិករដែលរារាំងការទទួលអត្ថប្រយោជន៍ និងការគាំទ្រពីកម្មវិធីនេះ។ បញ្ហាការប្រឈមទៅនឹងទោសទណ្ឌមួយចំនួន ជាពិសេសជុំវិញការបញ្ចេញការយល់ឃើញ ដែលត្រូវបានចាត់ទុកថាមិនមានប្រភពច្បាស់លាស់ ហាក់បីជាហេតុផលមួយដែលធ្វើឲ្យប្រជាកសិករដែលចូលរួមក្នុង

ការពិគ្រោះយោបល់ពីរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះ ជ្រើសរើសមិនធ្វើការបកស្រាយរែកញែកលម្អិតពីផលវិបាក និងឧបសគ្គរបស់ពួកគេនៅពេលទៅទទួលការគាំទ្រនៃកម្មវិធីនេះ។

## ៨. បំណុល និងហានិភ័យធ្លាក់ក្នុងវដ្តនៃបំណុល

ប្រជាកសិករ៧២.៨ភាគរយ ខ្ចីប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារ មុនពេលមានការផ្ទុះឡើងនៃមេរោគកូវីដ ១៩។ ពួកគេភាគច្រើន សុទ្ធសឹងកំពុងជំពាក់បំណុលពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬឯកទេស និងអ្នកចងការប្រាក់ឯកជន។ បញ្ហាបំណុល គឺជាមូលហេតុចម្បងមួយ ដែលនាំឲ្យសមាជិកពេញកម្លាំងនៅក្នុងគ្រួសារ ប្រជាកសិករមួយចំនួនត្រូវចំណាកស្រុក។



*កម្ចីមុនពេលកូវីដ១៩*

ប្រជាកសិករ២៩.៤ ភាគរយ ថាពួកគេ ខ្ចីបំណុលបន្ថែមដើម្បីផ្គត់ផ្គង់គ្រួសារ នៅអំឡុងពេលវិបត្តិពីមេរោគកូវីដ ១៩។ ក្នុងចំណោមប្រជាកសិករ ដែលជាប់បំណុលថ្មីបន្ថែម ក្នុងនោះចំនួន២៩.៤ភាគរយ ខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជនច្រើនជាងគេ ជាមួយមូលហេតុចម្បងដោយសារតែដំណើរការនៃការខ្ចីមានភាពងាយស្រួល និងរហ័សទាន់ចិត្ត។
ចំណែកឯប្រជាកសិករតិចជាង១០ភាគរយផ្សេងទៀត ប្រាប់ពួកគេឆ្លើយថាបានខ្ចីពីស្ថាប័ន មីក្រូហិរញ្ញវត្ថុឯកជន ឬធនាគារពាណិជ្ជ។



*បំណុលក្នុងពេលកូវីដ១៩*

ប្រជាកសិករ១៨.៣ភាគរយ ថាបំណុលដែលខ្លួនបានខ្ចីបន្ថែម គឺប្រើប្រាស់ដើម្បីសងបំណុលដែលពួកគេមានតាំងពីពេលមុនៗមក។ ក្នុងចំណោមប្រជាកសិករ ដែលខ្ចីបំណុលថ្មីដើម្បីទូទាត់សងបំណុលចាស់ មានប្រជាកសិករចំនួន៤៤.៤ភាគរយ ខ្ចីកម្ចីទាំងនោះពីអ្នកចង់ការប្រាក់ឯកជនជាមួយការប្រាក់ខ្ពស់ ដែលការប្រាក់ទាំងនោះមានកម្រិតខ្ពស់ជាង ស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជន ឬធនាគារពានិជ្ជ និងឯកទេស។




*ខ្ចីប្រាក់បន្ថែមដើម្បីសងបំណុលជំពាក់ពីមុន*

ប្រជាកសិករ៣៨.២ភាគរយ ដាក់ប្លង់ផ្ទះជាវត្ថុបញ្ចាំ ដើម្បីទទួលបានកម្ចីពីស្ថាប័នកម្ចីខាងលើ។ ប្រហាក់ប្រហែលគ្នានេះ ប្រជាកសិករ៣៥.៣ ដាក់ដីស្រែ ឬដីចំការដើម្បីជាទ្រព្យបញ្ចាំ។ គួរបញ្ជាក់ផងដែរថា រាល់ការខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬសូម្បីអ្នកចងការឯកជនមួយចំនួន ប្រជាកសិករតម្រូវឲ្យមានទ្រព្យ ឬរបស់របរដែលមានតម្លៃសម្រាប់ដាក់បញ្ចាំ។ បន្ថែមទៅលើការដាក់បញ្ចាំវត្ថុមានតម្លៃ ឬទ្រព្យសម្បត្តិ ប្រជាកសិករក៏តម្រូវឲ្យមានអ្នកធានាបំណុលដើម្បីទទួលបានកម្ចី។

ប្រជាកសិករជិតពាក់កណ្ដាល ថាពួកគេ (ដែលជាឪពុកម្ដាយ ឬប្ដីប្រពន្ធ) ទទួលខុសត្រូវក្នុងការសងបំណុល។ ហើយប្រជាកសិករស្មើរ៤០ភាគរយផ្សេងទៀត ថាកូនស្រីរបស់ពួកគេជាអ្នកទទួលខុសត្រូវសងបំណុលបន្ទាប់ពីឪពុកម្ដាយ។

*បទពិសោធន៍លំបាកក្នុងការសងបំណុល*




ប្រជាកសិករ៥១.១ភាគរយ ធ្លាប់មានការលំបាកក្នុងការសងបំណុលត្រឡប់ទៅ ស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជន ឬធនាគារពាណិជ្ជក្នុងអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩។ ប្រជាកសិករចំនួន៤៨.៩ភាគរយ បានដាក់ពាក្យស្នើសុំពន្យារពេលសងបំណុលត្រឡប់ទៅស្ថាប័នទាំងនោះ។ នៅពេលដែរប្រជាកសិករ ១០ភាគរយ ថាខ្លួនស្ថិតនៅក្នុងដំណើរការចរចាជាមួយស្ថាប័នផ្ដល់ប្រាក់កម្ចីទាំងនោះ

ដើម្បីស្នើសុំឲ្យមានការលើកពេលវេលាសង ឬក៏បន្ធូរបន្ថយការប្រាក់។ ជារឿយៗប្រជាកសិករ និងរកគ្រប់វិធីដើម្បីសងបំណុលត្រឡប់ទៅស្ថាប័នផ្តល់កម្ចី ក៏ប៉ុន្តែបញ្ហាដែលពួកគេនឹងប្រឈមការធ្លាក់កាន់តែជ្រៅទៅក្នុងវដ្តនៃបំណុល ដែលកំពុងស្ថិតនៅជាហានិភ័យខ្ពស់នៅឡើយ។ ការណ៍ នេះអាចបណ្តាលឲ្យមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរដល់សុខភាពផ្លូវចិត្តរបស់ពួកគេផងដែរ។ បញ្ហាបំណុល គឺជាបញ្ហាដ៏រ៉ាំរ៉ៃមួយនៅក្នុងចំណោមប្រជាកសិករ ហើយបញ្ហានេះធ្វើឲ្យគ្រួសារមួយចំនួនសម្រេចចិត្តលក់ទ្រព្យសម្បត្តិបន្តិចម្តងៗ និងវត្ថុមានតម្លៃដែលខ្លួនមានដើម្បីសងបំណុល។ ប្រជាកសិករមួយចំនួន បង្ហាញពីក្តីបារម្ភ និងភាពស្មុគស្មាញនៅពេលពិភាក្សាបញ្ហានេះជាពិសេសនៅក្នុងបរិ បទនៃវិបត្តិពីការរាតត្បាតនៃជំងឺ កូវីដ ១៩ កម្រិតនៃភាពស្មុគស្មាញជុំវិញលទ្ធភាពនៃការសងបំណុលត្រឡប់របស់ពួកគេ នឹងលំបាកដោះស្រាយជាមួយការកើនឡើងចំនួន។ មិនមានលទ្ធផលណាមួយពីការសិក្សាស្រាវជ្រាវនេះ ទាក់ទងទៅនឹងការរឹបអូសទ្រព្យ និងវត្ថុមានតម្លៃដោយស្ថាប័នផ្តល់កម្ចី ឬផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដែលបណ្តាលឲ្យប្រជាកសិករសម្រេចចិត្តសម្លាប់ខ្លួនដូចនៅប្រទេសដទៃនៅឡើយទេ។

## ៩. ស្ថានភាពទន្ទ្រានដីធ្លី ធនធានធម្មជាតិ និងជម្លោះដីធ្លីនាអំឡុងជំងឺកូវីដ១៩

ប្រជាកសិករ៦២.៥ភាគរយ ថាការរំលោភដីធ្លីពីគម្រោងវិនិយោគឯកជនធំៗ បទល្មើសនេសាទ បទល្មើសព្រៃឈើ អាជីវកម្មរុករករ៉ែ ជាដើម នៅបន្តកើតឡើងនៅក្នុងសហគមន៍ ដែលពួកគេកំពុងរស់នៅ។ ទំនាស់ដីធ្លី ទឹក ព្រៃឈើ និងធនធានធម្មជាតិ គឺជាជំងឺដ៏រ៉ាំរ៉ៃនៅកម្ពុជា ហើយដែលបានកើតមានស្ទើរគ្រប់ខេត្ត រវាងប្រជាកសិករជាមួយអ្នកមានអំណាច មានឥទ្ធិពល ឬជាមួយក្រុមហ៊ុនវិនិយោគធំៗ។



មុនពេលជំងឺកូវីដ១៩

ការចាក់ដីលុបឆ្នេរសមុទ្រ និងលុបព្រៃកោងកាងដើម្បីពង្រីកឆ្នេរធ្វើជាដីកម្មសិទ្ធិបុគ្គល ឬសម្រាប់ជាកន្លែងទេសចរណ៍ ដែលធ្លាប់ជាកន្លែងសម្រាប់មច្ឆជាតិពងនៅបន្តទទួលរងការបំផ្លិចបំផ្លាញឥតឈប់ឈរ។ ការសាងសង់ទំនប់វារីអគ្គិសនី ដែលធ្វើឲ្យប្រជាកសិករមួយចំនួនដែលរស់នៅក្នុងតំបន់នោះមានការព្រួយបារម្ភចំពោះផលប៉ះពាល់របស់វាមកលើជីវចម្រុះ ការធ្លាក់ចុះបន្ថែមទៀតនូវធនធានមច្ឆាជាតិ ឬបាត់បង់ពូជត្រីកម្រមួយចំនួនផលប៉ះពាល់មកលើជីវភាពរស់នៅ ជម្រក ទំនៀមទំន្លាប់ ប្រពៃណី និងវប្បធម៌របស់ពួកគេ។

ការទន្ទ្រានយកដីព្រៃលិចទឹកក្នុងតំបន់គ្រប់គ្រងសហគមន៍នេសាទ។ បើទោះជាសមាជិកសហគមន៍បានរាយការណ៍ជូនទៅស្ថាប័នជំនាញថ្នាក់ខេត្ត ស្រុក ឃុំ ព្រមទាំងអង្គការដៃគូអភិវឌ្ឍហើយយ៉ាងណាក្តី ក៏អាជ្ញាធរមួយចំនួនដែលបានចុះមើលជាក់ស្តែងមិនបានឆ្លើយតប ឬមានវិធានការនៅឡើយក្នុងករណីទន្ទ្រាននេះទេ។

ការនេសាទដោយប្រើឧបករណ៍ល្មើសច្បាប់ដូចជា ការប្រើប្រាស់ឧបករណ៍ឆក់ បរណាំវនៅតែបន្តជាពិសេសអ្នកនេសាទដែលមកពីខាងក្រៅតំបន់។ ប្រជានេសាទខ្លះក៏បានអូសលៀស ដែលធ្វើអោយប៉ះពាល់ដល់ទឹក និងត្រី (ពងកូន) នេះដោយសារពួកគេមិនមានមុខរបរ។

មានទាហាន និងអ្នកភូមិផ្សេងៗមួយចំនួនមកហ៊ុំព័ទ្ធដីព្រៃសហគមន៍ធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួន និងសម្រាប់ធ្វើកសិកម្ម។ ការណ៍នេះ អាចដំណើរការទៅបានដោយសារមានការឃុបឃិតជាមួយនឹងអាជ្ញាធរមូលដ្ឋានមួយចំនួន ដែលករណីដូចគ្នាក៏មានការកើតឡើងដែរក្នុងបរិបទបទល្មើសព្រៃឈើជាដើម។ ប្រជាពលរដ្ឋមួយចំនួនមានការកាប់ព្រៃឈើដើម្បីពង្រីកដីព្រៃបន្ថែម។

ប្រជាកសិករ២០.២ភាគរយ ថាមានករណីរំលោភបំពានថ្មីកើតឡើង នៅក្នុងសហគមន៍ ដែលនាំឲ្យមានការកើនឡើងនៃការកាប់ព្រៃឈើ និងការកាប់ទន្ទ្រានយកដីព្រៃទៅកាន់កាប់ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន នៅក្នុងអំឡុងពេលកូវីដ ១៩នេះ។ បញ្ហានៃការទន្ទ្រាន និងបទល្មើសព្រៃឈើថ្មីមួយផ្នែក គឺដោយសារ



*ក្នុងពេលកូវីដ១៩*

តែគណៈកម្មការសហគមន៍ការពារព្រៃឈើមានលទ្ធភាពតិចជាងមុនក្នុងការចុះល្បាតទប់ស្កាត់ និងការពារបទល្មើសទាំងនោះនៅក្នុងអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩។ ជនល្មើសបានឆក់ឱកាសនៃវិបត្តិនេះបន្តការកាប់ឈើ និងការរុករានព្រៃឈើសហគមន៍។

សម្រាប់គណៈកម្មការការពារព្រៃសហគមន៍ ឬអ្នកការពារព្រៃវិញ ស្ថានភាពរាល់ថ្ងៃនេះ គឺគ្រួសារមួយចំនួនស្ទើរតែដាច់បាយ ដែលកត្តានេះ ធ្វើឲ្យពួកគេមានភាពលំបាកក្នុងការចូលរួមការពារព្រៃឈើ។ ម្យ៉ាងទៀតដោយសារអាជ្ញាធរ កំពុងតែខ្វល់ខ្វាយអំពីការរីករាលដាលនៃជំងឺកូវីដ ១៩ ដូចនេះរបាយការណ៍ប្ដឹង ឬទាមទាររបស់ប្រជាពលរដ្ឋមួយចំនួនក៏ត្រូវបានផ្អាកដំណើរការដែរ។

បើទោះជាវិបត្តិកូវីដ១៩នៅបន្តក្នុងប្រទេសយើងយ៉ាងណាក្តី អាចកត់សម្គាល់បាននោះការប្រកាសសាលក្រមដល់អ្នកការពារដីធ្លី និងធនធានធម្មជាតិនៅតែបន្ត ដោយដាក់អោយជាប់គុក១ឆ្នាំ និងបង់ពិន័យ ២០០លានរៀល។ កំឡុងពេលនេះមេធាវីការពារក្តីកំពុងបន្តនីតិវិធីបណ្តឹងឧទ្ធរណ៍។ ប្រជាសហគមន៍ខ្លះទៀត ក៏មានការអាក់ខានក្នុងការប្តឹងផ្តល់ ដោយហេតុផលមួយចំនួនទាក់ទងនិងនិន្នាការបក្សប្រឆាំង។ នៅពេលដែលប្រជាសហគមន៍មិនអាចជួបជុំតវ៉ា វាបានបង្កើតជាឱកាសឲ្យជនល្មើស ឬក្រុមហ៊ុនខិលខូចប្រើឱកាសឬពេលវេលារៀបចំផែនការយុទ្ធសាស្ត្រអាក្រក់របស់ខ្លួនក្នុងការកាន់កាប់ និងទន្ទ្រានដីសហគមន៍។



*ការបៀតបៀន ការរើសអើង ឬអំពើហឹង្សា*

ប្រជាកសិករ៤៥.២ភាគរយ ធ្លាប់បានទទួលរងការបៀតបៀន រើសអើង ឬអំពើហិង្សាទាំងលើខ្លួនពួកគេ ឬសមាជិកនៅក្នុងគ្រួសាររបស់ពួកគ នាអំឡុងពេលនៃការផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ១៩។ សកម្មភាពនៃការរើសអើង និងបៀតបៀនមានទម្រង់ផ្សេងៗគ្នា។ ប្រជាកិសករមួយចំនួនថា ការរើសអើងកើតឡើងនៅពេលដែលសមាជិកគ្រួសាររបស់ពួកគេ មានជំងឺគ្រុនផ្តាសាយ។ ដោយសាររោគសញ្ញាជំងឺកូវីដ ១៩ ស្រដៀងទៅនឹងផ្តាសាយ ដូចនេះហើយការរើសអើងកើតមានដោយសារប្រជាពលរដ្ឋដទៃ មានការបារម្ភចំពោះការឆ្លងមេរោគនេះ។ ពួកគេថា ពួកគេធ្លាប់មានបទពិសោធ ត្រូវបានបដិសេធមិនព្រមព្យាបាលដោយហេតុផលថា ពេទ្យរវល់មានអ្នកជំងឺច្រើន។

មានការមិនទុកចិត្ត និងសង្ស័យទៅលើប្រជាកសិករដែលពាក់ម៉ាស។ ពួកគេទទួលការសម្មត់ថាមានផ្ទុកមេរោគកូវីដ ១៩ ដូចនេះប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ជាមួយគ្នាផ្សេងទៀត មិនហ៊ានចូលជិត ឬមិនហ៊ាននៅក្បែរពួកគេទាំងនោះឡើយ។ នៅពេលមានកូវីដ១៩ ប្រជាពលរដ្ឋមិនហ៊ាននិយាយរកគ្នាពិសេសអ្នកមកពីក្រៅស្រុក (អ្នកមកពីថៃ ឬអ្នកប្លែកមុខ)។

ក្រៅពីបម្រាម និងការរឹតត្បិតការជួបជុំនានារបស់សហគមន៍ដើម្បីទប់ស្កាត់នូវការរីករាលដាលនៃមេរោគកូវីដ ១៩ ប្រជាកសិករមួយចំនួន ពិសេសដែលស្ថិតនៅក្នុងបញ្ហាទំនាស់ដីធ្លី នៅបន្តទទួលរងការចោទប្រកាន់ពេលដែលពួកគេព្យាយាមប្រមូលផ្តុំទាមទារ ដីធ្លី និងយុត្តិធម៌ ដោយចោទប្រកាន់ថាជាក្រុមអ្នកប្រឆាំង ឬជាពួកឧទ្ទាម ហើយមួយចំនួនទៀតរងការចោទប្រកាន់ថាមាននិន្នាការគណបក្សប្រឆាំង។

## ១០. ផលប៉ះពាល់ផ្សេងៗទៀតមកលើប្រជាកសិករ

ប្រជាកសិករភាគច្រើន បានបង្ហាញពីក្តីបារម្ភណ៍យ៉ាងខ្លាំងទៅលើការគម្រាមកំហែងអាយុជីវិតមកលើក្រុមគណៈកម្មការសហគមន៍ដីធ្លីពីសំណាក់អ្នកមានអំណាច ដែលព្យាយាមរំលោភយកដីធ្លីក្នុងសហគមន៍មូលដ្ឋានមួយចំនួន។ ការគម្រាមកំហែង បានធ្វើឲ្យផលប៉ះពាល់ដល់អារម្មណ៍ធ្ងន់ធ្ងររបស់ប្រជាកសិករមួយចំនួន។

*"ទោះបីជាគណៈកម្មការការពាររបស់យើងខ្ញុំ បានទទួលស្គាល់ជាផ្លូវច្បាប់ក៏ដោយ ក៏ប៉ុន្តែនៅតែមានការគាបសង្កត់សិទ្ធិសេរីភាព នៅពេលដែលយើងចង់ធ្វើការប្រជុំម្តងៗ មានការតាមដាន ជូនកាល មិនទទួលបានការអនុញ្ញាតឲ្យពួកយើងមានការប្រជុំទៀត។"*

ប្រជាកសិករថាកូនចៅរបស់ពួកគេបានផ្អាកការសិក្សាដោយសារសាលារៀនផ្អាកដំណើរការ និងតម្រូវឲ្យរៀនតាមប្រព័ន្ធអ៊ិនធើណែតមួយរយៈមកហើយ។ ប្រជាកសិករភាគច្រើន ថាពួកគេមិនមានលទ្ធភាពទិញទូរស័ព្ទទំនើប ឬកុំព្យូទ័រឲ្យកូនៗរបស់ពួកគេដើម្បីជំនួយដល់ការរៀនសូត្រនោះទេ។ បន្ថែមទៅលើបញ្ហាប្រឈមនេះ ប្រជាកសិករមួយចំនួនថាខ្លួនជាឪពុកម្តាយដែលមិនសូវមានចំណេះលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបនូវឡើយនោះទេ ដូចនេះវាមានការលំបាកសម្រាប់ពួកគេនៅក្នុងការជួយតម្រែតម្រង់បង្រៀនកូនៗជាខ្លាំង។

## ១១. ការការពារខ្លួន និងវិធីសាស្ត្រដោះស្រាយ

ប្រជាកសិករមួយចំនួនចូលរួមផ្សព្វផ្សាយបន្តនៅក្នុងភូមិ និងសហគមន៍ពួកគេដើម្បីជម្រុញឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ដោយមានការលើកទឹកចិត្តឲ្យប្រជាកសិករដទៃទៀត ពាក់ម៉ាស ឬប្រើប្រាស់ក្រម៉ា លាងដៃជាមួយសាប៊ូ ឬទឹកអាកុលឲ្យបានញឹកញាប់ជាដើម។

ប្រជាកសិករ ថាពួកគេបន្តតាមដានព័ត៌មាន និងការផ្សព្វផ្សាយផ្សេងៗ ពីក្រសួងសុខាភិបាល។ ពួកគេបានអនុវត្តទៅតាមការកាត់បន្ថយការជួបជុំគ្នាជាសាធារណៈដែលមានអ្នកចូលរួមច្រើន រក្សាគំលាតរវាងគ្នា និងហូបអាហារដែលបានចំអិនត្រឹមត្រូវ។

ប្រជាកសិករមួយចំនួនបានកាត់បន្ថយចូលរួម ឬរៀបចំកម្មវិធីដែលមានការប្រមូលផ្តុំគ្នារវាងមនុស្សច្រើននាក់ដូចជា កម្មវិធីបុណ្យ កម្មវិធីមង្គលការ ឬការចេញចូលផ្សារដែលមិនចាំបាច់ និងការជួបជុំផឹកស៊ីជាដើម។ ប្រជាកសិករ បន្តរក្សាទំនាក់ទំនងជាមួយប្រជាកសិករនៅខេត្តដទៃ តាមរយៈប្រព័ន្ធទូរស័ព្ទ។

ប្រជាកសិករមួយចំនួន បានផ្សព្វផ្សាយ និងចែករំលែកវិធីសាស្ត្រនៃការដាំដុះ ចិញ្ចឹមសត្វ (មាន់ ទា ឬជ្រូក) ជាលក្ខណៈគ្រួសារ ទៅដល់ប្រជាកសិករដទៃ។ សម្រាប់ពួកគេ ការចែករំលែកចំណេះដឹងនេះ អាចជួយដល់ប្រជាកសិករមួយចំនួនទៀតដោះស្រាយបញ្ហាកង្វះស្បៀងអាហារបានខ្លះៗ នាអំឡុងពេលនៃវិបត្តិមេរោគកូវីដ ១៩។

មានសាមគ្គីភាពរវាងប្រជាកសិករនៅក្នុងសហគមន៍មូលដ្ឋានមួយចំនួន។ ការជួយគ្នាទៅវិញទៅមករួមមាន៖ ការចែករំលែកស្បៀងអាហារគ្នាហូប ឬការឲ្យខ្ចីស្បៀងគ្នាទៅវិញទៅមកនៅពេលខ្វះខាត ហើយនៅពេលប្រមូលផលស្រូវវិញទើបសងមកវិញជាដើម។ ប្រជាកសិករខ្លះទៀត បានព្យាយាមស្វះស្វែងរកជំនួយ និងការឧបត្ថមនានាពីខាងក្រៅដើម្បីជួយទៅដល់ប្រជាកសិករដទៃទៀតដែលក្រីក្រ ដោយពួកគេខ្វះខាតស្បៀងអាហារ ឬពុំមានលទ្ធភាពក្នុងការបង្កបង្កើនផលសម្រាប់ផ្គត់ផ្គង់ការហូបចុក។

ប្រជាកសិករមួយចំនួន បានបន្តអនុវត្តនូវការធ្វើស្រែចំការតាមបែបកៀ្សត្របរិស្ថាន ហើយការអនុវត្តប្រព័ន្ធដាំដុះបែបនេះ ធ្វើឲ្យពួកគេមានអាហារសម្រាប់ទទួលទានគ្រប់គ្រាន់។ ប្រជាកសិករមួយចំនួនទៀតបានបន្តចែករំលែកគ្រាប់ពូជដំណាំ ដែលពួកគេមិនចាំបាច់ចំណាយប្រាក់កាក់យកទៅដាំដុះដើម្បីជួយគ្នាទៅវិញទៅមក។

## ១២. ការគាំទ្រនានាពីអង្គការសង្គមស៊ីវិល

ប្រជាកសិករបានទទួលការគាំទ្រដូចជា៖ សម្ភារៈការពារខ្លួន (សាប៊ូ ឬ ទឹកអាកុល ម៉ាស ឬក្រម៉ា) ស្បៀងអាហារមួយចំនួនពីបណ្តាញប្រជាកសិករ ឬ បណ្តាញប្រជាជន និងពីអង្គការសង្គមស៊ីវិលមួយចំនួន។ ក៏ប៉ុន្តែការគាំទ្រទាំងនោះ ក៏មិនទាន់បានឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាកសិករនៅឡើយដែរ។

ប្រជាកសិករមួយចំនួន ដែលជាសមាជិកបណ្តាញកសិករមួយចំនួនបានឆ្លើយថាពួកគេទទួលបានការចែករំលែកបទពិសោធន៍ និងវគ្គបណ្តុះបណ្តាលពីការធ្វើកសិកម្មតាមបែបធម្មជាតិ ឬកៀ្សត្របរិស្ថានដូចជាទៅលើការដាំបន្លែ ចិញ្ចឹមសត្វ ធ្វើជីធម្មជាតិ និងថ្នាំសម្លាប់សត្វល្អិតធម្មជាតិជាដើម។

ប្រជាកសិករមួយចំនួនថា មានការបណ្តុះបណ្តាលយុវជនរួមទាំងការបង្រៀន ភាសាអង់គ្លេស និងកុំព្យូទ័រ បន្តមាននៅក្នុងសហគមន៍របស់ពួកគេ។ អង្គការសង្គមស៊ីវិលខ្លះ បានផ្សព្វផ្សាយផ្នែកច្បាប់អំពីដីធ្លី និងការវិភាគសង្គមជាដើមទៅដល់ប្រជាកសិករ។ មានការជួយសម្រួលលិខិតសម្រាប់ស្នើសុំទៅតុលាការពន្យារពេលស្រាយបំភ្លឺ និងទំនាក់ទំនងសួរសុខទុក លើកទឹកចិត្តទៅប្រជាកសិករ។

## ១៣. សេចក្តីសន្និដ្ឋាន

ផលប៉ះពាល់មួយចំនួនដែលបណ្តាលពីវិបត្តិនៃមេរោគកូវីដ ១៩ បានធ្វើឲ្យជីវភាពរស់នៅនិងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាកសិករកាន់តែលំបាកខ្លាំងឡើង រួមទាំងបង្កអោយមានវិបត្តិសុខភាពផ្លូវចិត្តរយៈពេលយូរអង្វែង។

ផងដែរនោះ ផលប៉ះពាល់បឋមធ្វើអោយពួកគេបាត់បង់នូវមុខរបរបណ្តោះអាសន្ន បន្តប្រឈមនឹងវិបត្តគ្មានទីផ្សារ ខូចខាតកសិផល បាត់បង់ប្រាក់ចំណូលដែលបណ្តាលឲ្យជីវភាពរបស់ពួកគេមានការធ្លាក់ចុះ។ បញ្ហាទីផ្សារមិនមែនជាបញ្ហាថ្មី ដែលទើបតែនឹងកើតឡើងនៅក្នុងប្រទេសកម្ពុជា នាអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ ១៩ នេះទេ ប៉ុន្តែបញ្ហានេះ បានបន្តកើតជាយូរឆ្នាំមកហើយ ហើយជានិច្ចកាលប្រជាកសិករខ្នាតតូច និងមធ្យមនៅមិនទាន់ទទួលបានទីផ្សារមួយដែលមានយុត្តិធម៌នៅឡើយទេ។ ផលិតផលកសិកម្មនិងដំណើរការសង្វាក់ផលិតកម្ម គឺស្ថិតក្នុងអំណាចគ្រប់គ្រងរបស់ក្រុមហ៊ុនកសិឧស្សាហកម្ម ឈ្មួញកណ្តាល ឬ អ្នកមានធនធាន និងមានអំណាចមួយចំនួន។ កង្វះស្បៀងអាហារដែលបណ្តាលមកពីបញ្ហានៃការបាត់បង់មុខរបរគឺជាកត្តាប្រឈមរបស់ប្រជាកសិករ ជាពិសេសប្រជាកសិករដែលផលិតដើម្បីចិញ្ចឹមប្រជាពលរដ្ឋដទៃទៀត។ បញ្ហាមួយចំនួនទៀតដែលត្រូវបានដឹងថាជាវិបត្តិដែលប្រៀបបានទៅនឹងជំងឺរ៉ាំរ៉ៃ បានកំពុងបន្តកើតឡើងនៅក្នុងសហគមន៍មូលដ្ឋានដូចជាការទន្ទ្រានដីធ្លី ព្រៃឈើ និងគម្រោងវិនិយោគមួយចំនួនដែលផ្តល់ផលប៉ះពាល់ដល់ការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត និងការវិចរិលនៃប្រភព និងធនធានទាំងនោះ។

បញ្ហាបំណុលក៏នៅជាបញ្ហាចម្បងរបស់ប្រជាកសិករ។ រហូតមកទល់ពេលនេះ បើទោះបីជាមានចេញនូវសារាចរណែនាំពីធនាគារជាតិនៃកម្ពុជា ជាពិសេសដើម្បីសម្រាលបន្ទុកដល់អ្នកខ្ចីប្រាក់ដែលកំពុងប្រឈមនឹងការធ្លាក់ចុះនៃប្រាក់ចំណូលចម្បង និងមានការលំបាកក្នុងការទូទាត់សងយ៉ាងណាក៏ដោយក៏សារាចរនេះនូវមិនទាន់មានប្រសិទ្ធិភាពនៅឡើយដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់ខ្លួន។

ចំណុចវិជ្ជមានដែលវិបត្តិនេះ នាំមកអោយប្រជាកសិករនោះគឺឱកាសនៃការជួបជុំគ្រួសារ បើទោះបីជាពួកគេមានផលវិបាកការការទ្រទ្រង់ និងធានាការមានទទួលទានគ្រប់គ្រាន់ក៏ដោយ។ តាមការអង្កេត ក៏មានការអនុវត្តដាំដុះជាលក្ខណៈគ្រួសារសម្រាប់ផ្គត់ផ្គង់តម្រូវការដោយផ្តោតជាអទិភាពទៅលើសុខភាព និងនិរន្តរភាពដី ហើយក៏បានឆ្លុះបញ្ចាំពីសារៈសំខាន់នៃការធ្វើកសិកម្មក្សេត្របរិស្ថានជាលក្ខណៈគ្រួសារ ឬដាំដំណាំនៅក្នុងដីរបស់ខ្លួននៅតែធ្វើជាធម្មតាបើទោះបីជាមានវិបត្តិក៏ដោយ។ ទោះជាយ៉ាងណាក្តីការពិនិត្យទៅលើការប្រើប្រាស់ បែងចែក និងគ្រប់គ្រងធនធានទឹកមានសារៈសំខាន់ណាស់ពិសេសពីសំណាក់រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ ដោយសារប្រសិនបើមិនមានការត្រួតពិនិត្យ គ្រប់គ្រងឲ្យបានត្រឹមត្រូវនោះទេ

ធនធានមួយនេះនឹងបន្តបាត់បង់បន្តិចម្តងៗ។ ការបែងចែកដោយយុត្តិធម៌គួរតែត្រូវពិនិត្យ និងអនុវត្តជាពិសេសការដកហូត ឬកំណត់ការប្រើប្រាស់ទៅលើក្រុមហ៊ុនធំៗ ឬអ្នកវិនិយោគជុំវិញធនធានទាំងនេះ។

រាជរដ្ឋាភិបាលត្រូវមានផែនការយុទ្ធសាស្ត្ររយៈពេលវែង និងខ្លីដើម្បីគាំទ្រទៅប្រជាពលរដ្ឋទាន់ពេល និងឆាប់រហ័សហើយជាពិសេសជនដែលងាយរងគ្រោះរួមមាន ជនពិការ ស្ត្រី កុមារ និងចាស់ជរាជាដើម។

## តម្រូវការ និងអនុសាសន៍

### ជូនរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធជុំវិញបញ្ហាជំងឺកូវីដ ១៩

- ស្នើរដ្ឋាភិបាលផ្តល់នូវថ្នាំវ៉ាក់សាំង និងបន្តផ្តល់សេវាថែទាំ និងព្យាបាលអ្នកជំងឺកូវីដ ១៩ ដោយមិនគិតថ្លៃ មានគុណភាព និងយកចិត្តទុកដាក់។
- ស្នើរដ្ឋាភិបាលផ្តល់ថវិកាសម្រាប់ប្រជាពលរដ្ឋដែលក្រីក្រ និងផ្គត់ផ្គង់ដល់គ្រួសារអ្នកដែលបានឆ្លងជំងឺនេះឱ្យបានទូលំទូលាយ។
- ស្នើរដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងដាក់ចត្តាឡីស័កដល់ប្រជាពលរដ្ឋ ដែលបានបាត់បង់ការងារ ឬប្រាក់ចំណូលប្រចាំថ្ងៃដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ។
- ស្នើរដ្ឋាភិបាលផ្តល់នូវជំនួយជាស្បៀងអាហារ និងឧបត្ថម្ភសម្ភារៈ ដូចជាសាប៊ូ ម៉ាស អាល់កុលដើម្បីគាំទ្រទៅដល់អ្នកក្រីក្រ ចាស់ជរា អ្នកគ្មានទីពឹង។
- រដ្ឋាភិបាលត្រូវមានគោលការណ៍បញ្ចុះតម្លៃទឹក និងភ្លើងដល់ប្រជាពលរដ្ឋទូទៅ។ស្នើរអោយមានវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងគ្រាអាសន្នដោយមានការចូលរួមពិគ្រោះយោបល់ជាមួប្រជាពលរដ្ឋ។
- ស្នើរដ្ឋាភិបាលបន្តចាត់វិធានរឹតត្បិតការចេញចូលក្នុងប្រទេសរបស់ជនបរទេស និងអនុវត្តចត្តាឡីស័ក តេស្ត ឬពិនិត្យឲ្យបានជាក់លាក់ជាមុនសិន។ ស្នើរដ្ឋាភិបាលចេញសេចក្តីប្រកាសពន្យាពេលសងការប្រាក់និងធ្វើកិច្ចអន្តរាគមន៍ដោយផ្ទាល់ជាមួយធនាគារពាណិជ្ជ ឬឯកទេស ស្ថាប័ន មីក្រូហិរញ្ញវត្ថុឯកជនក្នុងការអនុវត្តសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាកសិករខ្នាតតូច និងមធ្យមនៅអំឡុងពេលវិបត្តិនៃមេរោគកូវីដ ១៩។

### ជូនប្រជាកសិករ (សារជូនដល់ប្រជាកសិករ)

- ប្រជាកសិករ បន្តការពារខ្លួនជានិច្ច តាមការណែនាំរបស់ក្រសួងសុខាភិបាល។
- នៅពេលដែលសង្ស័យ ឬមានបញ្ហាសុខភាពពិសេសជុំវិញមេរោគកូវីដ ១៩ ត្រូវទៅពិនិត្យសុខភាពជាបន្ទាន់ដើម្បីបង្ការការចម្លងទៅប្រជាកសិករ និងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងសហគមន៍។
- ជួយផ្សព្វផ្សាយតៗគ្នា ដើម្បីការពារការឆ្លងរីករាលនៃមេរោគនេះ។

- ត្រូវទទួលទានទឹកស្អាត។
- បង្កើនការដាំដុះ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បីត្រៀមស្បៀងផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ។
- ត្រូវធ្វើកសិកម្មតាមបែបធម្មជាតិ ឬក្សេតបរិស្ថាន និងកសិដ្ឋានពហុប្រយោជន៍ជាលក្ខណៈគ្រួសារ។
- បន្តការចែករំលែកបទពិសោធន៍ ចំណេះដឹង ដោយប្រាប់តៗគ្នាក្នុងការដាំបន្លែ និងចិញ្ចឹមសត្វដើម្បីផ្គត់ផ្គង់ជីវភាពតាមដែលអាចធ្វើទៅបាន និងដើម្បីរកចំណូលផងដែរ។

## ជូនអង្គការសង្គមស៊ីវិល និងបណ្តាញប្រជាជន

- ស្នើឲ្យជួយគាំទ្រសម្ភារៈការពារខ្លួនដូចជាទឹកអាល់កុល សាប៊ូលាងដៃ ម៉ាស ក្រម៉ា និងពង្រឹងបន្ថែមពីវិធីសាស្ត្រការពារមេរោគកូវីដ ១៩ ដោយចុះផ្ទាល់ដល់មូលដ្ឋាន ឬតាមរយៈទូរស័ព្ទជាដើម។
- ស្នើជួយគាំទ្រស្បៀងអាហារសម្រាប់អ្នកក្រីក្រ និងអ្នកដែលខ្វះខាតអាហារសម្រាប់ទទួលទាន។
- ស្នើអោយមានភាពបត់បែនទៅលើផែនការសកម្មភាព អនុវត្តស្របជាមួយតម្រូវការរបស់ប្រជាកសិករ/អ្នកស្រែនៅក្នុងសហគមន៍មូលដ្ឋាន។
- ផ្តល់ព័ត៌មានអំពីស្ថានភាពនៃការវិវដ្តនៃមេរោគកូវីដ ១៩ ទាំងក្នុងប្រទេស និងថ្នាក់តំបន់ទៅដល់កសិករ/អ្នកស្រែនៅក្នុងសហគមន៍មូលដ្ឋានឲ្យបានទូលំទូលាយ។
- ស្នើអោយផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មទៅតាមបែបក្សេត្របរិស្ថាន ឬកសិកម្មធម្មជាតិ ទាំងការ ដាំដំណាំ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ហើយ ផ្តល់ពូជត្រី ពូជបន្លែទៅដល់កសិករ/អ្នកស្រែ។
- ស្នើបន្តការគាំទ្រសម្ភារៈ និងថវិកាសម្រាប់ដើរល្បាតព្រៃដូចជា វិទ្យុទាក់ទង ទូរស័ព្ទ និងប្រេងសាំងទៅដល់សហគមន៍មូលដ្ឋាន។
- ស្នើបន្តប្រឹក្សាយោបល់ផ្នែកច្បាប់ និងជួយការពារតាមនីតិវិធីសម្រាប់សហគមន៍ក្នុងបណ្តឹង ឬនៅពេលតុលាការកោះហៅ។
- ស្នើជជែកពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ លើសំណើរពន្យាពេលសងបំណុល និងការប្រាក់ជាមួយធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងម្ចាស់បំណុល នៅអំឡុងពេលមានជំងឺកូវីដ១៩ នេះ។
- ស្នើឲ្យអង្គការសង្គមស៊ីវិលមួយចំនួន ជួយនាំពាក្យទៅរដ្ឋាភិបាល ឲ្យជួយឧបត្ថម្ភស្បៀងដល់ប្រជាពលរដ្ឋក្រីក្រ ចាស់ជរា និងអ្នកគ្មានទីពឹងផងដែរ រួមទាំងសហការជាមួយរដ្ឋាភិបាលជំរុញឲ្យមានការធ្វើតេស្តមេរោគក្នុងសហគមន៍ និងទទួលបានថ្នាំវ៉ាក់សាំងការពារដោយឥតគិតប្រាក់។

## អនុសាសន៍ និងសំណើររបស់ប្រជាកសិករជូនរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធនៅលើបញ្ហារួមរបស់សហគមន៍

- ស្នើរដ្ឋាភិបាលឧបត្ថម្ភធន (ដី ទឹក ទុន) ដើម្បីជួយស្តារសេដ្ឋកិច្ចគ្រួសារ និងជីវភាពប្រជាកសិករខ្នាតតូច និងមធ្យម ក្នុងវិស័យកសិកម្មនៅកម្ពុជា។
- អន្តរាគមន៍ការពារធនធានធម្មជាតិ និងពង្រឹងការអនុវត្តច្បាប់ ដោយបញ្ឈប់អ្នកមានមុខតំណែងពីការប្រើប្រាស់អំណាច ឬបក្សពួកនិយម ដើម្បីគាបសង្កត់ប្រជាកសិករ គណៈកម្មការការពារព្រៃឈើសហគមន៍ និងសមាជិកសហគមន៍ជាដើម។រដ្ឋាភិបាលគួររឹតបណ្តឹងការចេញចូលតាមព្រំដែន ជាពិសេសការនាំចូលចំណីអាហារដែលគ្មានគុណភាព។
- ស្នើរដ្ឋាភិបាលជម្រុញឲ្យមានទីផ្សារយុត្តិធម៌សម្រាប់ផលិតកម្មកសិកម្ម។
- ទទូចឲ្យមានការពិនិត្យទៅលើលក្ខខណ្ឌនៃការផ្តល់ឥណទានរបស់ស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ធនាគារពាណិជ្ជ ឬឯកទេស ជាពិសេសសម្រាប់នីតិវីធីនៃការផ្តល់ប្រាក់ដល់ប្រជាកសិករខ្នាតតូច និងមធ្យម។
- ទទូចឲ្យមានការកាត់បន្ថយអាត្រាការប្រាក់កម្ចី និងអនុវត្តការលើកលែងមួយចំនួនសម្រាប់ប្រជាកសិករដែលមានការខ្វះខាតខ្លាំង។ស្នើរដ្ឋាភិបាលបង្កើតការងារក្នុងស្រុកឲ្យបានច្រើន និងផ្តល់ឱកាសដល់យុវជន ដើម្បីកាត់បន្ថយ ចំណាកស្រុកក្រៅប្រទេស ដោយបញ្ចូលនូវកិច្ចគាំពារសង្គមដល់ពួកគេ ព្រមជាមួយប្រាក់ខែសម រម្យ។
- ការលើកស្ទួយវិស័យកសិកម្មតាមបែបកក្សេត្របរិស្ថាន ជាពិសេសការចូលរួមដោយប្រជាកសិករខ្នាតតូច និងមធ្យម អាចនឹងចូលរួមកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋពេញកម្លាំង។ ប្រជាកសិករខ្នាតតូច និងមធ្យមនៅតែចូលរួមយ៉ាងសំខាន់ក្នុងការផលិតដើម្បីចិញ្ចឹមប្រជាពលរដ្ឋដទៃទៀតទូទាំងប្រទេស ដូចនេះលើកស្ទួយប្រជាកសិករ និងអ្នកស្រែជាភាពចាំបាច់ និងជាការស្តារជំនឿចិត្តចំពោះយុវជនជំនាន់ក្រោយទៅលើការពិចារណាការងារកសិកម្ម។
- ត្រូវពន្លឿនការដោះស្រាយទំនាស់ដីធ្លី និងអនុវត្តការបែងចែកដីធ្លីទៅដល់ប្រជាកសិករខ្នាតតូច និងមធ្យមដោយមានទំហំសមរម្យ (ដោយការពិគ្រោះយោបល់ជាមួយកសិករខ្នាតតូច និងមធ្យម) ការកសាង និងពង្រីកវិសាលភាពប្រព័ន្ធធារាសាស្ត្របន្ថែមទៀត (ស្រះទឹក អណ្តូង ស្តារស្រះ ឬប្រឡាយទឹក) និងការលើកទឹកចិត្តការប្រើប្រាស់ឧបករណ៍បូរាណដែលមិនតម្រូវឲ្យមានការចំណាយច្រើនទៅលើធាតុចូលកសិកម្ម និងការស្តារឡើងវិញពូជបូរាណជាជំហ៊ានចាំបាច់សម្រាប់កាត់បន្ថយបញ្ហាវិបត្តិមួយចំនួននៅពេលអនាគត ដើម្បីធានាឲ្យបាននូវអធិបតេយ្យភាពស្បៀង សម្រាប់ប្រជាពលរដ្ឋទាំងមូល និងជួយរក្សាស្ថេរភាពស្បៀងអាហារនៅក្នុងគ្រួសារ និងវិស័យកសិកម្មនៅកម្ពុជា។

- រដ្ឋាភិបាលគួរមានផែនការកំណត់ជាក់លាក់ណាមួយឲ្យប្រជាពលរដ្ឋមានការងារធ្វើក្នុងប្រទេសរបស់ខ្លួន ដើម្បីកាត់បន្ថយចំណាក់ស្រុកទៅក្រៅប្រទេស ប្រសិនបើបញ្ហាកូវីដ ១៩នេះ ត្រូវបានដោះស្រាយ។ ការបង្កើនការងារក្នុងស្រុកឲ្យច្រើនសម្រាប់ប្រជាពលរដ្ឋ កម្មករ និងយុវជន លើកទឹកចិត្តដល់ពួកគាត់ឲ្យធ្វើការងារក្នុងស្រុកយើងបាន។ ប្រសិនបើមានការងារក្នុងប្រទេសទទួលបានប្រាក់ខែសមរម្យ នោះប្រជាពលរដ្ឋមិនចាំបាច់ចំណាកស្រុកឡើយ។ យុវជនភាគច្រើនមានចំណេះដឹងខ្ពស់ និងបទពិសោធន៍ច្រើន គួរតែលើកទឹកចិត្តឲ្យមានការងារសមរម្យធ្វើក្នុងប្រទេសរបស់ខ្លួន។
- ពិនិត្យមើលទៅលើការបែងចែក ការប្រើប្រាស់ និងការគ្រប់គ្រងធនធានទឹកដោយយុត្តធម៌ ជាពិសេសវិធានការពិនិត្យទៅលើការប្រើប្រាស់ ឬទាញយកប្រភពធនធានទឹកពីក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនធំៗដែលធ្វើអាជីវកម្មពាក់ព័ន្ធនឹងទឹក អ្នកលក់ចែកចាយទឹកឯកជន ដែលប្រើប្រាស់ធនធានទឹកហួសហេតុដើម្បីបម្រើការរកស៊ី ឬជំនួញ និងបង្កើតប្រាក់ចំណេញរបស់ពួកគេ ដែលជាហេតុនាំឲ្យមានវិបត្តិទឹក ហើយនឹងបន្តឲ្យធនធានមួយនេះខ្សត់ខ្សោយទៅៗ។
- រដ្ឋាភិបាលគួរពង្រឹងការគ្រប់គ្រងឲ្យបានគ្រប់ជ្រុងជ្រោយ និងអនុវត្តដល់មូលដ្ឋាន ហើយមិនគួរស្តាប់តែរបាយការណ៍ដែលមានចរិតលក្ខណៈនិយាយលើកជើងនោះឡើយ ជាពិសេសពិនិត្យលើយន្តការដែលបានដាក់ចុះដើម្បីជម្រុញឲ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- រដ្ឋាភិបាលត្រូវត្រៀមស្បៀងទុកសម្រាប់គាំទ្រប្រជាពលរដ្ឋដែលគ្មានអាហារ ។
- រដ្ឋាភិបាលត្រូវដាក់កញ្ចប់ថវិកាដល់សេវាសុខាភិបាលឲ្យបានគ្រប់គ្រាន់ ក្នុងនោះត្រូវពង្រឹងលើគុណភាព និងផ្តល់សេវាដោយកុំឲ្យមានការរើសអើង និងត្រូវគោរពអនុវត្តតាមក្រមវិជ្ជាជីវៈរបស់ពេទ្យ។
- មានកញ្ចប់ថវិកាឧបត្ថម្ភធនដល់ប្រជាកសិករ/អ្នកស្រែខ្នាតតូច ឬ សហគមន៍មូលដ្ឋានដើម្បីបង្កើនការដាំដុះជាលក្ខណៈគ្រួសារ តាមបែបប្រព័ន្ធក្សេត្របរិស្ថាន ឬតាមបែបធម្មជាតិដែលវានឹងផ្តល់និរន្តរភាព សុខភាពល្អ និងការស្តារដីឡើងវិញ។
- ធនាគារជាតិគួរមានវិធានការលើបញ្ហាប្រាក់កម្ចី និងបំណុល ដើម្បីជួយដល់ប្រជាពលរដ្ឋដែលទទួលរងពីផលប៉ះពាល់ក្នុងអំឡុងនៃវិបិត្តិកូវីដនេះ។

## ឯកសារយោង

### ច្បាប់ និងសេចក្តីប្រកាស

1. សេចក្តីជូនដំណឹង លេខ ១២៩ សជណអរហ ចុះថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័កពស ២៥៦៣ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ ស្តីពីការបិទ KTV ក្លឹបកំសាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក) នៅគ្រប់រាជធានីខេត្តជាបណ្តោះអាសន្នចាប់ពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ រហូតដល់មានការជូនដំណឹងជាថ្មី ដោយក្រសួង ទេសចរណ៍។
2. សេចក្តីជូនដំណឹង លេខ១៣១៣ សហវ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីវិធានការអន្តរាគមន៍បន្ទាន់របស់រាជរដ្ឋាភិបាលដើម្បីទ្រទ្រង់វិស័យទេសចរណ៍ វិស័យកាត់ដេរសំលៀកបំពាក់ ស្បែកជើង និងកាបូប និងកំណើនសេដ្ឋកិច្ច ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

   https://www.mef.gov.kh/measures-of-tax.html
3. សេចក្តីជូនដំណឹង ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់ឥណទានគាំទ្រ សិប្បកម្មសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកែច្នៃផលិតផលកសិកម្ម វិស័យកសិ-ឧស្សាហកម្ម និងវិស័យកសិកម្មតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មក្រោមកម្មវិធីហិរញ្ញប្បទានពិសេសរបស់រដ្ឋាភិបាល ដោយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

   https://dap-news.com/national/2020/03/18/41661/
4. សេចក្តីជូនដំណឹង លេខ ០០៣ សជណ ចុះថ្ងៃព្រហស្បត្តិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ សេចក្តីណែនាំ ស្តីពីការផ្សព្វផ្សាយអំពីវិធានការបង្ការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយក្រសួងមហាផ្ទៃ។
5. សេចក្តីជូនដំណឹងលេខ ៩១៦ សជណ ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្អាកជាបណ្តោះ អាសន្ននូវការធ្វើដំណើរចេញពីប្រទេសរបស់ប្រជាពលរដ្ឋកម្ពុជា ទៅកាន់ សាធារណរដ្ឋសង្គមនិយមវៀតណាម និងការធ្វើដំណើរចូលព្រះរាជាណាចក្រ កម្ពុជារបស់ប្រជាពលរដ្ឋវៀតណាម ដោយក្រសួងមហាផ្ទៃ។
6. សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិស្សមកាល តូចមិនមានកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាចំណោះទូទៅសាធារណៈ និងឯកជននៅរាជធានីភ្នំពេញ និងក្រុងសៀមរាប ក្នុងបរិបទនៃការ រីករាលដាលនៃជំងឺ កូវីដ១៩។
7. សេចក្តីជូនដំណឹង លេខ ១០០៧ សជណ ថ្ងៃសុក្រ ៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០ ស្តីពីវិធានការគ្រប់គ្រងបងប្អូន ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ ដោយ ក្រសួងមហាផ្ទៃ។
8. សារាចរណ៍ណែនាំ លេខធ៧ ០២០ ០០១ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ១៩

ដោយធនាគាជាតិនៃកម្ពុជា។
https://drive.google.com/file/d/1ZhbKO93V7XIm1CnCbaG5_jUmNE4W0PHl/view

9. សេចក្តីជូនដំណឹង លេខ០០៧ សហរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការបញ្ឈប់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនកាស៊ីណូជាបណ្តោះអាសន្ន និងការលើកលែងការបង់ពន្ធពីការតព្វកិច្ចចំណូលប្រចាំខែ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
10. សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ស្តីពីការដាក់ដំណើរការ "គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម" ដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ https://www.mef.gov.kh/pr-launch-20200403.html
11. បទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០២ ប.ប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្តីពី ការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេសក្នុងគោលដៅបង្ការ និងទប់ស្កាត់ការ រាតត្បាតនៃជំងឺកូវីដ ១៩។ https://www.kohkong.gov.kh/2020/41943/
12. សេចក្តីណែនាំ លេខ ០៥៦/២០ កប/សណន.ខ.ល ចុះថ្ងៃសុក្រ ១០រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ សេចក្តីណែនាំស្តី ពីវិធានការចត្តាឡីស័កចំពោះកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថានដែលបានឈប់សម្រាកក្នុងអំឡុងពេលបុណ្យចូលឆ្នាំ និងចូលរបម្រើការ ងារវិញ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។
13. អនុក្រឹត្យ លេខ៥០ អនក្រ.បក ស្តីពី ការលើកការឈប់សម្រាកការងាររបស់ មន្ត្រីរាជការ និយោជិតកម្មករ នៅថ្ងៃ១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នា២០២០ ដោយទីស្តីការគណៈរដ្ឋមន្ត្រី។ https://pressocm.gov.kh/archives/65579
14. ព្រះរាជក្រម នស/រកម/០៤២០/០១៨ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយទីស្តីការគណៈរដ្ឋមន្ត្រី។ https://pressocm.gov.kh/archives/65972
15. សេចក្តីជូនព័ត៌មានចុះថ្ងៃសៅរ៍ ទី១៥ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីពីមានករណីជាសះស្បើយ ០៤នាក់ និងមិនមានករណីវិជ្ជមានវីរុសកូវីដ ១៩ ថ្មី នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដោយវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## **របាយការណ៍**

16. វីអូអេ កម្ពុជាប្រកាសករណីទី១នៃវីរុសកូរ៉ូណាដែលរកឃើញលើជនជាតិចិនម្នាក់ នៅខេត្តព្រះសីហនុ ថ្ងៃទី២៧ខែមករាឆ្នាំ២០២០។ សូមទាញឯកសារពីគេហទំព័រ៖ https://khmer.voanews.com/a/first-case-of-coronavirus-confirmed-in-Cambodia/5261841.html
17. វីអូអេ ពលរដ្ឋបារម្ភខ្លាចគ្រឹះស្ថានឥណទានរឹបអូសទ្រព្យបញ្ចាំជាងបារម្ភអំពីវីរុសកូរ៉ូណា ថ្ងៃទី១៦

ខែឧសភា ឆ្នាំ២០២០។ សូមទាញឯកសារពីគេហទំព័រ៖ https://khmer.voanews.com/a/families-fear-banks-more-than-virus-as-loans-loom-over-their-heads/5421925.html

18. របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ ១៩ លេខ ១៩៨ អង្គការសុខភាពពិភព លោកទទួលបានរបាយការណ៍ពីអាជ្ញាធរជាតិនៃប្រទេសសមាជិកនាម៉ោង ១១:០០ ស៊ីធីអេសធី ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០។ សូមទាញឯកសារពីគេហ ទំព័រ៖https://www.who.int/docs/default-source/coronaviruse/situation-reports/20200805-covid-19-sitrep-198.pdf?sfvrsn=f99d1754_2
19. អត្ថបទវិភាគ "មេរោគកូរ៉ូណា vs វិសមភាព" របស់អង្គការសហប្រជាជាតិផ្តោត លើការអភិវឌ្ឍ។ សូមទាញឯកសារពីគេហទំព័រ៖ https://feature.undp.org/coronavirus-vs-inequality/
20. សេចក្តីសង្ខេប "ផលប៉ះពាល់របស់ជំងឺកូវីដ ១៩ ទៅលើស្ត្រី និងកុមារី" របស់អង្គការសហប្រជាជាតិផ្តោតលើស្ត្រី។ សូមទាញឯកសារពីគេហទំព័រ៖ https://interactive.unwomen.org/multimedia/explainer/covid19/en/index.html?gclid=EAIaIQobChMIiJDtyt626wIVkXZgCh1WmQSVEAAYASAAEgJBr_D_BwE
21. របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ ១៩ លេខ ៨៣ "អង្គការសុខភាពពិភពលោក ទទួលបានរបាយការណ៍ពីអាជ្ញាធរជាតិនៃប្រទេសសមាជិកនាម៉ោង ១០:០០ ស៊ីអ៊ីធី ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០។សូមទាញឯកសារពីគេហទំព័រ៖https://www.who.int/docs/default-source/coronaviruse/situation-reports/20200412-sitrep-83-covid-19.pdf?sfvrsn=697ce98d_4
22. ការអង្កេតនេះ ត្រូវបានធ្វើឡើងតាមរយៈការប្រមូល និងតាមដានព័ត៌មានពីការ វិវឌ្ឍនានាទាំងសេចក្តីជូនរបស់រាជរដ្ឋាភិបាល ការប្រព្រឹត្តិទៅរបស់ប្រជាពលរដ្ឋ នៅតាមទីសាធារណៈ និងការធ្វើបច្ចុប្បន្នភាពនៃស្ថានភាពជាមួយប្រជាពលរដ្ឋរស់ នៅក្នុងខេត្តមួយចំនួន។
23. សម្រង់ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ពីធីប្រកាសដាក់ឲ្យដំណើរការជាផ្លូវការ "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ ១៩"។ អត្ថបទនេះដកស្រង់ចេញពីគេហ ទំព័រ កម្ពុជាទស្សនៈថ្មី។
24. "បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" អង្គការច្បាប់អន្តរជាតិអេហ្វអាយឌីអេជនិងក្រុមអ្នកការពារសិទ្ធិមនុស្សស៊ីវិល។ សូមទាញឯកសារពីគេហទំព័រ៖ https://www.fidh.org/IMG/pdf/20200407_cambodia_analysis_soe_bp_kh.pdf
25. "បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" អង្គការច្បាប់អន្តរជាតិអេហ្វអាយឌីអេជ និងក្រុមអ្នកការពារសិទ្ធិមនុស្សស៊ីវិល។សូមទាញឯកសារពីគេហទំព័រ៖https://www.fidh.org/IMG/pdf/20200407_cambodia_analysis_soe_bp_kh.pdf

26. Por Ir, Bart Jacobs, Augustine D Asante, Marco Liverani, Stephen Jan, Srean Chhim, and Virginia Wiseman គោលនយោបាយសុខាភិបាល និងការរៀបចំផែនការ "ស្វែងយល់ពីកត្តាកំណត់នៃការផ្តល់ហិរញ្ញប្បទានក្នុងកំឡុងបញ្ហាសុខភាពអាសន្ននៅកម្ពុជា" ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយ Oxford Academic។ សូមទាញឯកសារពីគេហទំព័រ៖ https://academic.oup.com/heapol/article/34/Supplement_1/i26/5603549
27. ច្រឹក សុភា "វិបត្តិតម្លៃស្រូវបច្ចុប្បន្ន៖ ព្រឹត្តិការណ៍ដែលបង្ហាញពីបញ្ហាជាប្រព័ន្ធ" ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ដោយកម្មវិធីផ្តោតលើលោកខាងត្បូង។ សូមទាញឯកសារពីគេហទំព័រ៖ https://focusweb.org/current-paddy-rice-price-crisis-wake-up-call-on-a-more-systemic-problem/

រៀបចំ និងផលិតដោយៈ

អាសយដ្ឋានៈ ផ្ទះលេខ១៦៨AZ ផ្លូវលេខ២៧BT សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ខែសីហា ឆ្នាំ២០២០